សម្តេចប្រធានរដ្ឋសភា និងឯកឧត្តមប្រធានព្រឹទ្ធសភាប៉ាគីស្ថាន ប្តេជ្ញាពង្រឹង កិច្ចសហប្រតិបត្តិការសភាប្រទេសទាំងពីរ ដើម្បីលើកកម្ពស់ផលប្រយោជន៍ប្រជាពលរដ្ឋ

សម្តេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា និង ឯកឧត្តម **ស៊ីយ៉េដ យូសាហ្វ រ៉ាហ្សា ហ្គីឡានី** (Syed Yusaf Raza Gilani) ប្រធានព្រឹទ្ធសភា នៃសាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន បានប្តេជ្ញាចិត្តរួមគ្នាក្នុងការលើកកម្ពស់កិច្ចសហប្រតិបត្តិការទំនាក់ទំនងប្រជាជននៃប្រទេសទាំងពីរ ឱ្យកាន់តែជិតស្និទ្ធឡើងស្របតាមចំណងមិត្តភាព កិច្ចសហប្រតិបត្តិការដ៏ល្អរវាងប្រទេសទាំងពីរ ដែលឈរយ៉ាងរឹងមាំ ស្មោះត្រង់ ជឿទុកចិត្តគ្នា ដោយរក្សាប្រយោជន៍ជូនពលរដ្ឋទាំងសងខាង។ ការលើកឡើងដូច្នេះនៅក្នុងឱកាសជំនួបពិភាក្សាការងាររវាង សម្តេចរដ្ឋសភាធិបតី **ឃួន សុដារី** ជាមួយ ឯកឧត្តម **ស៊ីយ៉េដ យូសាហ្វ រ៉ាហ្សា ហ្គីឡានី** នាព្រឹកថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២៦ នៅវិមានរដ្ឋសភា ខណៈដែល ឯកឧត្តមប្រធានព្រឹទ្ធសភាបានដឹកនាំគណៈប្រតិភូមកបំពេញទស្សនកិច្ចផ្លូវការ និងមិត្តភាពនៅព្រះរាជាណាចក្រកម្ពុជា តបតាមការអញ្ជើញរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា។

សម្តេចរដ្ឋសភាធិបតីបានសម្តែងក្តីសោមនស្សរីករាយ និងស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានរបស់ **ឯកឧត្តមប្រធានព្រឹទ្ធសភា** និងបានចាត់ទុកការអញ្ជើញមកដល់នេះ ជាផ្នែកដ៏សំខាន់មួយធ្វើឱ្យទំនាក់ទំនងប្រទេសទាំងពីរកាន់តែរីកចម្រើនបន្ថែមទៀត ទាំងក្នុងក្របខ័ណ្ឌស្ថាប័ននីតិប្បញ្ញត្តិ និងស្ថាប័ននីតិប្រតិបត្តិ។

សម្តេចប្រធានបានអបអរសាទរចំពោះភាពជោគជ័យថ្មីៗរបស់ប៉ាគីស្ថាន ក្នុងការរៀបចំសន្និសីទប្រធានសភានៃអន្តរសភា (ISC) កាលពីខែវិច្ឆិកាកន្លងទៅ និងបានចេញសេចក្តីប្រកាសគាំទ្រចំពោះកិច្ចព្រមព្រៀងសន្តិភាពកម្ពុជា-ថៃ ដោយបានជំរុញឱ្យភាគីទាំងពីរ ដោះស្រាយជម្លោះព្រំដែន ដោយសន្តិវិធី និងឱ្យមានប្រសិទ្ធភាពខ្ពស់។

ឯកឧត្តមប្រធានព្រឹទ្ធសភាប៉ាគីស្ថានបានសម្តែងការអរគុណ **សម្តេចប្រធានរដ្ឋសភា** ដែលបានទទួលស្វាគមន៍យ៉ាងកក់ក្តៅបំផុត ជាពិសេស **ឯកឧត្តម**បានថ្លែងអរគុណ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** និងប្រជាពលរដ្ឋកម្ពុជាទាំងអស់ ដែលបានទទួលគណៈប្រតិភូរបស់ **ឯកឧត្តម** យ៉ាងកក់ក្តៅជាទីបំផុត។

ឯកឧត្តមប្រធានព្រឹទ្ធសភាបានវាយតម្លៃខ្ពស់ចំពោះការរីកចម្រើនគ្រប់វិស័យនៅកម្ពុជា និងបានគូសបញ្ជាក់ថា **ឯកឧត្តម**បានអញ្ជើញមកកម្ពុជាចំនួន ៣លើករួចមកហើយ ពោលគឺនៅឆ្នាំ២០១៩ បន្ទាប់មកឆ្នាំ២០២៣ ដែលពេលនោះ **ឯកឧត្តម**ក៏បានចូលរួមសង្កេតការណ៍បោះឆ្នោតនៅកម្ពុជាផងដែរ និងលើកទី ៣នេះ ជាដំណើរទស្សនកិច្ចក្នុងនាម**ឯកឧត្តម**ជាប្រធានព្រឹទ្ធសភាប៉ាគីស្ថាន។

សម្តេចប្រធានរដ្ឋសភា និង**ឯកឧត្តមប្រធានព្រឹទ្ធសភាប៉ាគីស្ថាន** ក៏បានពិភាក្សាបន្ថែមទៀតពីការជំរុញនិងលើកកម្ពស់ទំនាក់ទំនង ពង្រីកកិច្ចសហប្រតិបត្តិការរវាងរដ្ឋសភាកម្ពុជា និងព្រឹទ្ធសភាប៉ាគីស្ថាននិងប្រជាជននៃប្រទេសទាំងពីរឱ្យកាន់តែជិតស្និទ្ធ ដែលនេះ ជាមូលដ្ឋានគ្រឹះក្នុងការឈានដល់ការពង្រឹងកិច្ចសហប្រតិបត្តិការបន្ថែមទៀតលើវិស័យពាណិជ្ជកម្ម ទេសចរណ៍ អប់រំ វប្បធម៌ បច្ចេកវិទ្យាព័ត៌មាន និងកសិកម្ម ជាដើម។ រដ្ឋសភាកម្ពុជានិងព្រឹទ្ធសភាប៉ាគីស្ថាននឹងបន្តជំរុញឱ្យមានកិច្ចសហប្រតិបត្តិការ និងការផ្លាស់ប្តូរដំណើរទស្សនកិច្ចទាំងកម្រិតថ្នាក់ដឹកនាំកំពូល ក្រុមមិត្តភាព និងកម្រិតអគ្គលេខាធិការដ្ឋាន។

ថ្នាក់ដឹកនាំសភាប្រទេសទាំងពីរបានឯកភាពគ្នាពីសារៈសំខាន់ក្នុងការគោរពច្បាប់អន្តរជាតិ ការរក្សាប្រយោជន៍រួម និងជំរុញឱ្យមានសុខសន្តិភាព វិបុលភាពមនុស្សជាតិ មិនថាប្រទេសតូច ឬប្រទេសធំនោះទេ ត្រូវគោរពអធិបតេយ្យគ្នា និងឱ្យតម្លៃគ្នាទៅវិញទៅមក។

សម្តេចរដ្ឋសភាធិបតី **ឃួន សុដារី** បានស្នើដល់ភាគីប៉ាគីស្ថាន ឱ្យពិចារណាក្នុងការផ្សារភ្ជាប់ជើងហោះហើរត្រង់រវាងប្រទេសទាំងពីរ។ **សម្តេច**បានជម្រាប **ឯកឧត្តមប្រធានព្រឹទ្ធសភាប៉ាគីស្ថាន** ថា សម្តេចតេជោ **ហ៊ុន សែន** បានទទួលយកសំណើរបស់**ឯកឧត្តម**ក្នុងការរៀបចំសន្និសីទប្រធានសភានៃអន្តរសភា លើកទី២ នៅឆ្នាំ២០២៦។ **សម្តេចប្រធាន**បានលើកឡើងពីសុខដុមនីយកម្មសាសនានៅកម្ពុជាដែលបានដើរតួនាទីដ៏សំខាន់ក្នុងការរក្សាបានសុខសន្តិភាព និងការអភិវឌ្ឍ។

ជាមួយគ្នានេះ ឯកឧត្តម **ស៊ីយ៉េដ យូសាហ្វ រ៉ាហ្សា ហ្គីឡានី** បានប្រកាសថា ប៉ាគីស្ថាននឹងគាំទ្រកម្ពុជា ដើម្បីក្លាយជាសមាជិកអង្គការឥស្លាម (OIC) ហើយ **ឯកឧត្តម**សង្ឃឹមថា កម្ពុជានឹងបើកស្ថានទូតជាផ្លូវការនៅប៉ាគីស្ថានក្នុងពេលឆាប់ៗខាងមុខនេះ ៕

ប្រធានរដ្ឋសភាកម្ពុជា-វៀតណាម ជំរុញការលុបបំបាត់ព័ត៌មានក្លែងក្លាយ ដែលបំផ្លាញដល់ផលប្រយោជន៍ពលរដ្ឋនៃប្រទេសទាំងពីរ





សម្តេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភា បានលើកឡើងនូវគំនិតផ្តួចផ្តើមឱ្យរដ្ឋសភាកម្ពុជា និងវៀតណាមបង្កើនកិច្ចសហការគ្នាឱ្យបានស្អិតល្មួតបន្ថែមទៀតក្នុងការប្រយុទ្ធប្រឆាំង «ព័ត៌មានក្លែងក្លាយ» ដែលអាចជាហេតុប៉ះពាល់ដល់សន្តិសុខបំណងមិត្តភាព និងការអភិវឌ្ឍនៃប្រទេសទាំងពីរកម្ពុជា-វៀតណាមក៏ដូចជាក្នុងតំបន់ផងដែរ។ ការលើកឡើងនេះ បានធ្វើឡើងក្នុងជំនួប ពិភាក្សាការងារជាមួយ ឯកឧត្តម **ត្រឹន ថាញ់ មិន** (Tran Thanh Man) ប្រធានរដ្ឋសភាវៀតណាម នាថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៦ នៅវិមានរដ្ឋសភា ខណៈដែល **ឯកឧត្តម**បានអមដំណើរ **ឯកឧត្តម តូ ឡឹម** (To Lam) អគ្គលេខាធិការបក្សកុម្មុយនីស្តវៀតណាម អញ្ជើញមកបំពេញទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា។

សម្តេចប្រធានរដ្ឋសភា បានទទួលស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានរបស់**ឯកឧត្តមប្រធានរដ្ឋសភា**ដែលបានអញ្ជើញមកកាន់កម្ពុជា ជាថ្មី។

សម្តេចបានវាយតម្លៃខ្ពស់ ចំពោះលទ្ធផលនៃកិច្ចប្រជុំត្រីភាគីរវាងគណបក្សទាំងបីប្រទេស (កម្ពុជា វៀតណាម និងឡាវ) ដែលបានប្រព្រឹត្តទៅនាពេលនេះនិងសម្រេចបានលទ្ធផលគួរជាទីមោទនៈហួសពីការរំពឹងទុក និងជាមាគ៌ាយ៉ាងសំខាន់មួយ សម្រាប់ការអនុវត្តក្នុងការលើកកម្ពស់កិច្ចសហប្រតិបត្តិការប្រទេសទាំងបីឱ្យកាន់តែរឹងមាំរីកចម្រើនរួមគ្នាបន្ថែមទៀត។ ក្នុងឱកាសនោះ **សម្តេច**ក៏បានរំលឹកពីទស្សនៈរបស់ឯកឧត្តម **តូ ឡឹម** ដែលបានថ្លែងក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំគណបក្សនយោបាយនៃប្រទេសទាំងបី ពីការពង្រឹងបន្ថែមទៀតនូវបំណងមិត្តភាពជាប្រពៃណីរវាងប្រទេសកម្ពុជា វៀតណាមនិងឡាវដែលត្រូវបន្តជួយគាំទ្រគ្នាទៅវិញទៅមកក្នុងការដោះស្រាយបញ្ហានានា និងជំរុញការអភិវឌ្ឍប្រកបដោយចីរភាព វិបុលភាព សម្រាប់ប្រជាពលរដ្ឋនៃប្រទេសទាំងបី។



ប្រធានរដ្ឋសភាកម្ពុជា និងវៀតណាមបានគូសបញ្ជាក់ថា រដ្ឋសភានៃប្រទេសទាំងពីរតែងគាំទ្រគ្នាទៅវិញទៅមកនៅលើវេទិកាអន្តរសភានានា ដើម្បីការពារប្រយោជន៍ពលរដ្ឋ។ថ្នាក់ដឹកនាំរដ្ឋសភាប្រទេសទាំងពីរបានសន្យាថា នឹងជំរុញការផ្លាស់ប្តូរ ដំណើរទស្សនកិច្ច និងការចែករំលែកបទពិសោធន៍ រវាងរដ្ឋសភាប្រទេសទាំងពីរឱ្យកាន់តែសកម្ម ទាំងកម្រិតថ្នាក់ដឹកនាំ ក្រុមមិត្តភាព សមាជិករដ្ឋសភាស្ត្រី សមាជិករដ្ឋសភាវ័យក្មេង និងអគ្គលេខាធិការដ្ឋាន។



សម្តេចប្រធានរដ្ឋសភាបានសាទរចំពោះផែនការអភិវឌ្ឍរបស់ប្រទេសវៀតណាម ដែលមានបក្ខវិស័យវែងឆ្ងាយ ក្នុងការអភិវឌ្ឍខ្លួនទៅជាប្រទេសអភិវឌ្ឍន៍ នៅឆ្នាំ២០៤៥។

ជាមួយគ្នានេះ ឯកឧត្តម **ត្រឹន ថាញ់មិន** មានជំនឿយ៉ាងមុតមាំថា គោលដៅអភិវឌ្ឍន៍របស់កម្ពុជា ក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសអភិវឌ្ឍន៍ នៅឆ្នាំ ២០៥០ នឹងសម្រេចជោគជ័យជាក់ជាមិនខាន។

នៅក្នុងឱកាសនោះ **សម្តេចរដ្ឋសភាធិបតី** ក៏បានគោរពអញ្ជើញឯកឧត្តម **ត្រឹន ថាញ់មិន** ចូលរួមសន្និសីទប្រធានសភានៃអន្តរសភា(ISC)ដែលកម្ពុជានឹងធ្វើជាម្ចាស់ផ្ទះ នាពេលខាងមុខ។

សម្តេចប្រធានរដ្ឋសភាបានថ្លែងអំណរគុណដល់ប្រទេសវៀតណាម ដែលបានផ្តល់ជំនួយសាងសង់អគាររដ្ឋបាលថ្មីដល់រដ្ឋសភាកម្ពុជា និងបានសម្ពោធដាក់ឱ្យប្រើប្រាស់ កាលពីឆ្នាំកន្លងទៅ។

សម្តេចបានគូសបញ្ជាក់ថា អគាររដ្ឋបាលថ្មីនេះបានក្លាយជាអគារពហុវិស័យ និងសម្រួលការងារជាច្រើន ដល់អគ្គលេខាធិការដ្ឋានរដ្ឋសភា។

ថ្នាក់ដឹកនាំកំពូល នៃស្ថាប័ននីតិប្បញ្ញត្តិ នៃប្រទេសទាំងពីរ បានប្តេជ្ញាចិត្តរួមគ្នាបន្តអនុវត្តរាល់កិច្ចព្រមព្រៀងដែលប្រទេសទាំងពីរ បានឯកភាពគ្នាឱ្យមានប្រសិទ្ធភាព សម្រេចបានសមិទ្ធផលកាន់តែច្រើនឡើងក្នុងការលើកកម្ពស់ជីវភាពនិងតម្រូវការរបស់ប្រពលរដ្ឋនៃប្រទេសទាំងពីរ៕

សម្តេចប្រធានរដ្ឋសភា អញ្ជើញចូលរួមពិធីលៀងសាយភោជនផ្លូវរដ្ឋ ជូន ឯឧត្តមអគ្គលេខាធិការមជ្ឈិមបក្សកុម្មុយនីស្តវៀតណាម



សម្តេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភាកម្ពុជា អញ្ជើញចូលរួមក្នុងពិធីលៀងសាយភោជនផ្លូវរដ្ឋ ដែលរៀបចំដោយ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ក្នុងព្រះបរមនាម ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជូន ឯកឧត្តម **តូ ឡឹម** (To Lam) អគ្គលេខាធិការមជ្ឈិមបក្សកុម្មុយនីស្តវៀតណាមនិងគណៈប្រតិភូជាន់ខ្ពស់ នៅវិមានសាមគ្គីភាពនៃព្រឹទ្ធសភានារាត្រីថ្ងៃទី៦ខែកុម្ភៈឆ្នាំ២០២៦ ។

សម្តេចតេជោ **ហ៊ុន សែន** បានថ្លែងអបអរសាទរចំពោះ ឯកឧត្តម **តូ ឡឹម** ដែលត្រូវបានមហាសន្និបាតតំណាងទូទាំងប្រទេស លើកទី១៤ របស់បក្សកុម្មុយនីស្តវៀតណាម បោះឆ្នោតជ្រើសតាំងសាជាថ្មី ជាអគ្គលេខាធិការនៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តវៀតណាម កាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៦។

សម្តេចតេជោ បានថ្លែងនូវអំណរគុណដល់ **ឯកឧត្តមអគ្គលេខាធិការបក្ស** និងគណៈប្រតិភូជាន់ខ្ពស់ ដែលបានចំណាយពេលវេលាដ៏មមាញឹក និងមានតម្លៃ អញ្ជើញមកបំពេញទស្សនកិច្ចផ្លូវរដ្ឋនៅកម្ពុជា។ កម្ពុជានិងវៀតណាម តែងផ្លាស់ប្តូរដំណើរទស្សនកិច្ចផ្លូវរដ្ឋទៅវិញទៅមក ដើម្បីបន្តរឹតចំណងមិត្តភាព សាមគ្គីភាព ក្នុងស្មារតីជាអ្នកជិតខាងល្អនឹងគ្នារហូតមក។

តាមរយៈការផ្លាស់ប្តូរទស្សនកិច្ចថ្នាក់ដឹកនាំគ្រប់កម្រិតនេះ ក៏បានរួមចំណែកធ្វើឱ្យទំនាក់ទំនងនៃប្រទេសទាំងពីរ ទាំងផ្នែកនយោបាយ សេដ្ឋកិច្ច ពាណិជ្ជកម្ម វប្បធម៌ ទេសចរណ៍ និងវិស័យផ្សេងៗទៀត កាន់តែមានភាពសកម្ម និងមមាញឹកទ្វេដង បម្រើដល់ផលប្រយោជន៍ នៃប្រទេសទាំងពីរ និង តំបន់ផងដែរ៕



សម្តេចរដ្ឋសភាធិបតី ឃួន សុដារី៖ មហាសាមគ្គីជាតិខ្មែរ
ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលជាកត្តាសំខាន់បំផុតក្នុងកិច្ចការពារបូរណភាពទឹកដី



សម្តេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភា មានប្រសាសន៍លើកឡើងពីសារៈសំខាន់ នៃកម្លាំងសាមគ្គីមហាគ្រួសារខ្មែរក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលថា ជាកត្តាសំខាន់បំផុតក្នុងកិច្ចការការពារអធិបតេយ្យ និងបូរណភាពទឹកដី។ **សម្តេច**បានថ្លែងអំណរគុណដល់ពលរដ្ឋខ្មែរទាំងអស់ ទាំងក្នុង និងក្រៅប្រទេសដែលបានរួមគ្នាជាធ្លុងមួយឈរការពារ និងគាំទ្ររាជរដ្ឋាភិបាល និងវីរយុទ្ធជនយើង ក្នុងកិច្ចការពារអធិបតេយ្យ និងបូរណភាពទឹកដី តាំងពីដើមរហូតមក។

សម្តេចប្រធានរដ្ឋសភាបានលើកឡើងដូច្នេះ ក្នុងឱកាសអញ្ជើញទទួលអំណោយសប្បុរសធម៌ជាថវិកា និងសម្ភារមួយចំនួនពី លោកជំទាវ **ឈាង គឹមស៊ុន** ទីប្រឹក្សាសម្តេចប្រធានរដ្ឋសភា និងលោកជំទាវ **នាង សុវណ្ណារី** ទីប្រឹក្សាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សម្រាប់ចែកជូនដល់វីរៈកងទ័ព និងជនភៀសសឹករបស់យើង នៅវិមានរដ្ឋសភា នាព្រឹកថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៦។

សម្តេចប្រធានរដ្ឋសភាបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះសន្ដានចិត្តប្រកបដោយសប្បុរសធម៌របស់លោកជំទាវទាំងពីររូប ក៏ដូចជាសប្បុរសជនទាំងអស់ ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជាកម្លាំងសប្បុរសធម៌ មហាគ្រួសារខ្មែរ តាមរយៈ**សម្តេច**ក្តី និងតាមរយៈថ្នាក់ដឹកនាំស្ថាប័ននានាក្តី ដែលទាំងនេះសុទ្ធសឹងជាកាយវិការមនុស្សធម៌ គួរជាទីគោរពបំផុត ស្របតាមការអំពាវនាវរបស់រាជរដ្ឋាភិបាល ក៏ដូចជាថ្នាក់ដឹកនាំកំពូលរបស់ជាតិ ក្នុងស្មារតីមហាគ្រួសារខ្មែរ ជួយសង្គ្រោះជាតិក្នុងគ្រាដ៏លំបាកនេះ។

សម្តេចរដ្ឋសភាធិបតី **ឃួន សុដារី** បានគូសបញ្ជាក់ថា គោលការណ៍អាទិភាពសំខាន់បំផុតរបស់រាជរដ្ឋាភិបាល ទាំងពេលកន្លងមក បច្ចុប្បន្ន និងទៅអនាគត គឺអធិបតេយ្យ បូរណភាពទឹកដី និងអាយុជីវិតប្រជាពលរដ្ឋ។ កិច្ចការពារបូរណភាទឹកដីត្រូវបានការពារដោយច្បាប់អន្តរជាតិ ហើយកម្ពុជាមិនទទួលស្គាល់ដាច់ខាត ការកែប្រែខ្សែបន្ទាត់ព្រំដែន ឬការកាន់កាប់ទឹកដីដោយខុសច្បាប់អន្តរជាតិ ឬតាមរយៈការប្រើប្រាស់កម្លាំង។ កម្ពុជាប្រកាន់ខ្ជាប់ការដោះស្រាយបញ្ហាព្រំដែនជាមួយថៃ ដោយសន្តិវិធី ស្របតាមច្បាប់អន្តរជាតិ ព្រមទាំងកិច្ចព្រមព្រៀងដែលមានស្រាប់រវាងកម្ពុជា-ថៃ។

ជាពិសេស ការបុះវាស់វែងតាមយន្តការគណៈកម្មការចម្រុះខណ្ឌសីមាព្រំដែនគោក (JBC) ដើម្បីកំណត់ភាពត្រឹមត្រូវ និងយុត្តិធម៌របស់ប្រទេសទាំងពីរក្នុងការការពារអធិបតេយ្យ និងបូរណភាពទឹកដីរៀងៗខ្លួន។

សម្តេចប្រធានរដ្ឋសភា បានលើកឡើងថា មហាសាមគ្គីគ្រួសារខ្មែរ បានរួមគ្នាជាធ្លុងមួយ ផុសឡើងយ៉ាងរឹងមាំ និងខ្លាំងក្លាជាទីបំផុតមិនធ្លាប់មាន ក្នុងគ្រាដែលប្រទេសជាតិ ជួបការលំបាកនេះ។ នៅគ្រប់ប្រទាប់វណ្ណៈ ប្រជាពលរដ្ឋ ព្រះសង្ឃ មន្ត្រីរាជការ ថ្នាក់ដឹកនាំ រហូតដល់ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង។ មហាសាមគ្គីជាតិខ្មែរ ជាកម្លាំងចលករដ៏សំខាន់ឈរយ៉ាងស្វាហាប់ ពីក្រោយរាជរដ្ឋាភិបាល និងវីរយុទ្ធជនរបស់យើង ជាខឿនដ៏រឹងមាំការពារប្រទេសជាតិក្នុងនាម«ខ្មែរជួយខ្មែរ» នៅគ្រប់កាលៈទេសៈជាមួយរាជរដ្ឋាភិបាល។

ក្នុងស្មារតីសមរភូមិក្រោយគាំទ្រ និងនៅជាប់ជានិច្ចជាមួយសមរភូមិមុខ ទាំងថ្នាក់ដឹកនាំរដ្ឋសភា សមាជិក សមាជិការដ្ឋសភា ព្រមទាំងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា បានចូលរួមយ៉ាងសស្រាក់សស្រាំ ទាំងថវិកា កម្លាំងកាយចិត្ត បុះសួរសុខទុក្ខ និងចែកអំណោយសប្បុរសធម៌ជូនវីរយុទ្ធជន និងប្រជាពលរដ្ឋភៀសសឹកនៅគ្រប់គោលដៅ។

អំណោយដែល **សម្តេចប្រធានរដ្ឋសភា** ទទួលបាននាពេលនេះ គឺពីលោកជំទាវ **គឹម ស៊ុន** មានអង្ករផ្កាម្លិះចំនួន ២តោន ទឹកបរិសុទ្ធ ៥០កេស សាច់ក្រក ៥០គីឡូក្រាម ប្រហុក ៥០គីឡូក្រាម និងអំណោយទទួលបានពីលោកជំទាវ **នាង សុវណ្ណារី** មានត្រីងៀតចំនួន ៥០គីឡូក្រាម មីជាតិ ៥០កេស និងផ្លែប៉ូវ ៥០គីឡូក្រាម។

ចំពោះអំណោយសប្បុរសធម៌ ដែលរដ្ឋសភាទទួលបានតាមរយៈ **សម្តេចប្រធានរដ្ឋសភា** បានធ្វើការបែងចែកជូនដល់រដ្ឋបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃ រួមមានខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ខេត្តកោះកុង សម្រាប់ធ្វើការបែងចែកបន្តជូនដល់វីរៈកងទ័ព និងពលរដ្ឋភៀសសឹក។

ក្រៅពីនេះ ថវិកា និងសម្ភារមួយចំនួនទៀត សម្រាប់ចែកជូនវីរយុទ្ធជន ដែលកំពុងសម្រាកព្យាបាលនៅតាមមន្ទីរពេទ្យ និងសម្រាប់ជូនក្រុមគ្រួសារវីរយុទ្ធជន ដែលបានពលីជីវិតជាដើម៕

ឈរលើមាគ៌ាសន្តិភាព រដ្ឋសភាកម្ពុជានិងបារាំង ពង្រឹងកិច្ចសហប្រតិបត្តិការស៊ីជម្រៅ និងសកម្មបន្ថែមទៀត ក្នុងការរក្សាប្រយោជន៍កាន់តែច្រើនជូនប្រជាពលរដ្ឋ



សម្តេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា និង ឯកឧត្តម **តូម៉ាស់ ឡាំ** (Thomas Lam) សមាជិករដ្ឋសភា និងជាប្រធានក្រុមមិត្តភាពរដ្ឋសភាបារាំង-កម្ពុជា បានឯកភាពគ្នាពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការរវាងរដ្ឋសភាប្រទេសទាំងពីរ ឱ្យកាន់តែសកម្ម ស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយបន្ថែមទៀត ដើម្បីនាំមកនូវផលប្រយោជន៍កាន់តែច្រើន ជូនពលរដ្ឋ។ ជាមួយគ្នានេះ ភាគីទាំងពីរបានវាយតម្លៃខ្ពស់ចំពោះតម្លៃសន្តិភាព ដែលជាមូលដ្ឋានគ្រឹះដ៏សំខាន់ក្នុងការឈានឆ្ពោះទៅសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs)។

នៅក្នុងជំនួបពិភាក្សា នាថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៦ សម្តេចរដ្ឋសភាធិបតី **ឃួន សុដារី** បានទទួលស្វាគមន៍យ៉ាងកក់ក្តៅបំផុត ចំពោះវត្តមានរបស់គណៈប្រតិភូក្រុមមិត្តភាពរដ្ឋសភាបារាំង-កម្ពុជា ដឹកនាំដោយ ឯកឧត្តម **តូម៉ាស់ ឡាំ** ដែលបានអញ្ជើញមកបំពេញទស្សនកិច្ចនៅកម្ពុជា ចាប់ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៦ តបតាមការអញ្ជើញរបស់ **សម្តេច**។

ដំណើរទស្សនកិច្ចនេះ ជាទំព័រប្រវត្តិសាស្ត្រថ្មីមួយក្នុងការរឹតចំណងមិត្តភាព ជាប្រវត្តិសាស្ត្ររវាងកម្ពុជា-បារាំង ដែលមានតាំងពីយូរលង់មក ឱ្យកាន់តែរឹងមាំថែមទៀត។ **សម្តេច**បានគូសបញ្ជាក់ថា បារាំងជា មិត្តចាស់ មិត្តដែលទុកចិត្ត ជឿជាក់ និងបានផ្តល់ផលប្រយោជន៍ទៅវិញទៅមក។

ឯកឧត្តម **តូម៉ាស់ ឡាំ** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរដ្ឋសភាកម្ពុជា ដែលបានទទួលស្វាគមន៍យ៉ាងកក់ក្តៅ នូវដំណើរទស្សនកិច្ចរបស់គណៈប្រតិភូរដ្ឋសភាបារាំង នាឱកាសនេះ។ ឯកឧត្តមបានគូសបញ្ជាក់ថា ដំណើរទស្សនកិច្ចនេះ ជាផ្នែកសំខាន់មួយក្នុងការជំរុញចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិរវាងប្រទេសទាំងពីរឱ្យកាន់តែរឹងមាំឡើង។ជាមួយគ្នានេះដំណើរទស្សនកិច្ចក៏ជាផ្នែកមួយបន្ថែមទៀត ដែលនឹងធ្វើឱ្យការរៀបចំកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនី លើកទី២០ និងដំណើរទស្សនកិច្ចរបស់ឯកឧត្តមប្រធានាធិបតីបារាំង **អេម៉ានុយអែល ម៉ាក្រុង** (Emmanuel Macron) នៅកម្ពុជា នាខែវិច្ឆិកា ខាងមុខនេះ ឱ្យទទួលបានលទ្ធផលជាទីគាប់ចិត្តផងដែរ។

សម្តេចប្រធានរដ្ឋសភា បានលើកឡើងថា ក្រុមមិត្តភាពបារាំង-កម្ពុជាដើរតួនាទីដ៏សំខាន់ក្នុង

ការពង្រឹងចំណងមិត្តភាព និងទំនាក់ទំនងប្រជាជន និងប្រជាជននៃប្រទេសទាំងពីរ។ កម្ពុជាបានផ្តល់តម្លៃខ្ពស់ចំពោះកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនី ដែលមិនត្រឹមជាវេទិកាសម្រាប់ភាសាបារាំងប៉ុណ្ណោះទេតែជាកិច្ចសន្ទនា ជាការជួបជុំថ្នាក់ដឹកនាំកំពូលៗ ជាច្រើន ដើម្បីដោះស្រាយបញ្ហារួមរបស់ពលរដ្ឋ។

វេទិកានេះ ជាផ្នែកដ៏សំខាន់មួយក្នុងការពង្រឹងសុខសន្តិភាព គោលការណ៍ពហុនិយមរបស់សកលលោក ដែលកំពុងធ្លាក់ចុះគួរឱ្យព្រួយបារម្ភ។

សម្តេចរដ្ឋសភាធិបតី **ឃួន សុដារី** បានថ្លែងអំណរគុណដល់សាធារណរដ្ឋបារាំង ដែលបានរួមចំណែកស្វែងរកសន្តិភាពនៅកម្ពុជា និងចូលរួមយ៉ាងសកម្មក្នុងដំណើរការកសាង និងអភិវឌ្ឍ នៅកម្ពុជារហូតមក។ **សម្តេច**ក៏បានអរគុណសមាជិករដ្ឋសភាបារាំង និងក្រុមមិត្តភាពបារាំង-កម្ពុជា ដែលបានចេញញត្តិ គាំទ្រកិច្ចព្រមព្រៀងសន្តិភាពកម្ពុជា-ថៃ និងបានជំរុញឱ្យប្រទេសទាំងពីរអនុវត្តឱ្យមានប្រសិទ្ធភាព ឈានឆ្ពោះទៅបញ្ចប់ជម្លោះព្រំដែនដោយសន្តិវិធី។ ញត្តិគាំទ្រនោះ បានឆ្លុះបញ្ចាំងឱ្យពិភពលោកបានដឹងថា ភាគីណាជាជនរងគ្រោះ និងភាគីណាជាអ្នកឈ្លានពាន។



ឯកឧត្តមប្រធានគណៈប្រតិភូបានអបអរសាទរចំពោះកម្ពុជា ដែលទទួលធ្វើជាម្ចាស់កិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនី លើកទី២០ និងជូនពរ ឱ្យកម្ពុជាទទួលបានជោគជ័យ ហើយភាគីបារាំងបានត្រៀមខ្លួនជាស្រេចក្នុងការគាំទ្រដល់ការរៀបចំកិច្ចប្រជុំនេះ ឱ្យទទួលបានជោគជ័យ។

ឯកឧត្តម **តូម៉ាស់ ឡាំ** បានបញ្ជាក់ថា ដំណើរទស្សនកិច្ចរបស់ ឯកឧត្តមប្រធានាធិបតីបារាំង មកកម្ពុជា ស្របពេលកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនី ដែលនឹងធ្វើឱ្យប្រទេសទាំងពីរ រកឃើញនូវលទ្ធភាពជាច្រើនបន្ថែមទៀត ក្នុងការពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការជាមួយគ្នា។ ទាក់ទងជម្លោះព្រំដែនកម្ពុជា-ថៃ បារាំងត្រៀមផ្តល់ឯកសារដើម ដែលខ្លួនមានដល់កម្ពុជា។

សម្តេចប្រធានរដ្ឋសភាបានថ្លែងអំណរគុណរដ្ឋសភាបារាំង ដែលបានគាំទ្រដល់រដ្ឋសភាកម្ពុជា ក្នុងការអភិវឌ្ឍស្ថាប័នជាសភាឌីជីថល និងស្នើដល់រដ្ឋសភាបារាំងបន្តផ្តល់ការបណ្តុះបណ្តាលវគ្គខ្លីៗ ដល់មន្ត្រីអគ្គលេខាធិការដ្ឋានរដ្ឋសភាបន្ថែមទៀត។ **សម្តេច**បានស្នើសុំភាគីបារាំង ជំរុញការវិនិយោគ ពាណិជ្ជកម្ម ទេសចរណ៍បន្ថែមទៀតមកកាន់កម្ពុជា ជាពិសេស ពិនិត្យលទ្ធភាពក្នុងការភ្ជាប់ជើងហោះហើរត្រង់បារាំង-កម្ពុជា ឡើងវិញផងដែរ៕

សម្តេចរដ្ឋសភាធិបតី ឃួន សុដារី៖ ឯកអគ្គរាជទូតត្រូវធ្វើការដោយទន់ភ្លន់ ម៉ឺងម៉ាត់ តម្កល់ប្រយោជន៍ពលរដ្ឋ និងប្រទេសជាតិជាធំ

សម្តេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា មានប្រសាសន៍ថា ឯកអគ្គរាជទូត មិនត្រឹមតំណាងឱ្យក្រសួងការបរទេសប៉ុណ្ណោះទេ តែជាតំណាងឱ្យប្រទេសជាតិ តំណាងឱ្យព្រះមហាក្សត្រ និងប្រជាជនកម្ពុជាទាំងមូល។ បេសកកម្មការទូត ជាការងារដ៏ឧត្តុង្គឧត្តម ត្រូវការពារឱ្យបាននូវផលប្រយោជន៍ប្រទេសជាតិ និងការលើកកម្ពស់កិត្យានុភាពជាតិនៅលើឆាកអន្តរជាតិ។ ឯកអគ្គរាជទូត ត្រូវធ្វើការដោយភាពទន់ភ្លន់ ម៉ឺងម៉ាត់ និងត្រូវតម្កល់ផលប្រយោជន៍ពលរដ្ឋ និងប្រទេសជាតិជាធំ។

សម្តេចប្រធានរដ្ឋសភា បានលើកឡើងដូច្នេះ នៅក្នុងឱកាសអនុញ្ញាតជូន ឯកអគ្គរាជទូតកម្ពុជា ទើបទទួលបានការតែងតាំង ទៅបំពេញបេសកកម្មការទូតនៅបណ្តាប្រទេសនានា ចំនួនបួនរូប ចូលជួបសម្តែងការគួរសម ទទួលអនុសាសន៍ និងជម្រាបលា នៅព្រឹកថ្ងៃ២៤ ខែកុម្ភៈ ឆ្នាំ២០២៦ រួមមាន ឯកឧត្តម **ណុំ ពិសិដ្ឋ** ឯកអគ្គរាជទូត ប្រចាំប្រទេសអូស្ត្រាលី និងណូវែលហ្សេឡង់ លោកជំទាវ **ទូច សុផារត្ន** ឯកអគ្គរាជទូត ប្រចាំសាធារណរដ្ឋសង្គមនិយមវៀតណាម ឯកឧត្តម **ឆាយ មករា** ឯកអគ្គរាជទូត ប្រចាំរដ្ឋកូវ៉ែត និងឯកឧត្តម **ផូ សំអាង** ឯកអគ្គរាជទូត ប្រចាំសាធារណរដ្ឋគុយបា។

សម្តេចប្រធានរដ្ឋសភា មានក្តីសោមនស្សរីករាយនិងស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានរបស់ឯកឧត្តមលោកជំទាវ ដែលត្រូវបានរាជរដ្ឋាភិបាលអាណត្តិទី៧ ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយថាមវន្តរបស់ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី ផ្តល់សេចក្តីទុកចិត្តតែងតាំងជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅបណ្តាប្រទេសនានា។

សម្តេចរដ្ឋសភាធិបតី **ឃួន សុដារី** បានគូសបញ្ជាក់ថា បេសកកម្មការទូតពិតជាសំខាន់ខ្លាំង និងបំពេញបន្ថែមលើកិច្ចខិតខំប្រឹងប្រែងរបស់អ្នកនៅក្នុងប្រទេស ដោយរួមចំណែកការពារ និងលើកកម្ពស់អត្តសញ្ញាណជាតិ កំណើនសេដ្ឋកិច្ច និងស្ថិរភាពជាតិ។ ដើម្បីឈានសម្រេចបានគោលបំណងនេះ ក្នុងនាមមន្ត្រីការទូត ចាំបាច់ត្រូវមានសមត្ថភាពក្នុងការសម្របសម្រួលយ៉ាងជិតស្និទ្ធរវាងការទូតរបស់រដ្ឋ ការទូតសភា និងការទូតផ្សេងៗ ដូចជាការទូតសេដ្ឋកិច្ច ការទូតប្រជាជន ជាដើម៕

សម្តេចរដ្ឋសភាធិបតី ឃួន សុដារី អញ្ជើញថ្វាយព្រះរាជដំណើរ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងនិងសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ស្តេចយាងទៅពិនិត្យព្រះរាជសុខភាព នៅរដ្ឋធានីប៉េកាំង

សម្តេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា នាព្រឹកថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៦ បានអញ្ជើញថ្វាយព្រះរាជដំណើរ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជានិងសម្តេចព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ក្នុងព្រះរាជសកម្មភាព ស្តេចយាងទៅពិនិត្យព្រះរាជសុខភាព តាមការកំណត់ នៅរដ្ឋធានីប៉េកាំង សាធារណរដ្ឋប្រជាមានិតចិន។

វត្តមានដ៏ខ្ពង់ខ្ពស់របស់ **សម្តេចរដ្ឋសភាធិបតី ប្រធានរដ្ឋសភា**ថ្វាយព្រះរាជដំណើរនាឱកាសនេះ បានស្តែងឱ្យឃើញយ៉ាងប្រត្យក្សនូវការយកចិត្តទុកដាក់ខ្ពស់ និងការគោរពដឹងគុណយ៉ាងជ្រាលជ្រៅបំផុតរបស់ស្ថាប័ននីតិប្បញ្ញត្តិ ថ្វាយចំពោះអង្គព្រះមហាក្សត្រ និងសម្តេចព្រះវររាជមាតាជាតិខ្មែរ ដែលព្រះអង្គទាំងទ្វេគឺជាម្លប់ដ៏ត្រជាក់ត្រជុំ និងជានិមិត្តរូបនៃឯកភាពជាតិ សេចក្តីសុខសាន្ត របស់ប្រជារាស្ត្រខ្មែរគ្រប់រូប។

អញ្ជើញថ្វាយព្រះរាជដំណើរដែមហេឡារិកនៅអាកាសយានដ្ឋានអន្តរជាតិតេជោ ក្នុងខេត្តកណ្តាល នាពេលនេះ មានវត្តមានដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ ដែលនឹងទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី ក្នុងអំឡុងពេលអវត្តមានរបស់ព្រះមហាក្សត្រ ព្រមទាំងវត្តមានដ៏ខ្ពង់ខ្ពស់ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី។ ជាមួយគ្នានេះ ក៏មានការយាង និងអញ្ជើញចូលរួមពីរាជវង្សានុវង្ស ថ្នាក់ដឹកនាំជាន់ខ្ពស់ សមាជិក សមាជិកានៃស្ថាប័នព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាល ព្រមទាំងវត្តមានរបស់ ឯកអគ្គរដ្ឋទូតសាធារណរដ្ឋប្រជាមានិតចិន ប្រចាំកម្ពុជាផងដែរ។

ក្នុងឱកាសដ៏វិសេសវិសាលនេះ សម្តេចរដ្ឋសភាធិបតី **ឃួន សុដារី** រួមជាមួយសមាជិក សមាជិកានៃរដ្ឋសភាជាតិទាំងអស់ សូមលំឱនកាយក្រាបបង្គំថ្វាយព្រះរាជសព្ទសាធុការពរជ័យ បវរមហាប្រសើរ ថ្វាយព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និងសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ សូមព្រះអង្គ

ទាំងទ្រង់ស្តេចយាងប្រកបដោយសុវត្ថិភាព តាមព្រះរាជហឫទ័យប្រាថ្នា និងសូមឱ្យលទ្ធផលនៃការពិនិត្យព្រះរាជសុខភាព ទទួលបាននូវភាពល្អប្រសើរជាទីបំផុត ដើម្បីព្រះអង្គគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ត្រជុំដល់ប្រជានុរាស្ត្រខ្មែរគ្រប់រូប រស់នៅក្នុងសុខសន្តិភាព វិបុលភាព និងសុភមង្គល ជានិរន្តរ៍តរៀងទៅ។

ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ខាម យៀប ដឹកនាំកិច្ចប្រជុំផ្សព្វផ្សាយប្រតិទិនការងារអន្តរសភាអាស៊ាន (AIPA) សម្រាប់ឆ្នាំ២០២៦

ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ខាម យៀប** អនុប្រធានទី១ រដ្ឋសភា នៅព្រឹកថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៦ បានអញ្ជើញជាអធិបតីដឹកនាំកិច្ចប្រជុំផ្សព្វផ្សាយប្រតិទិនការងារ ប្រចាំឆ្នាំ២០២៦ របស់អន្តរសភាអាស៊ាន (AIPA)។

កិច្ចប្រជុំនេះ បានផ្តោតលើរបៀបវារៈការងារសំខាន់ៗរួមមាន ការរំលឹកអំពីសមាសភាពទទួលបន្ទុកតាមគណៈកម្មាធិការនានារបស់អាយប៉ា និងការពិភាក្សាលើការត្រៀមលក្ខណៈចូលរួមកិច្ចប្រជុំអន្តរជាតិនានា ក្នុងឆ្នាំ២០២៦នេះ ដោយមានការចូលរួមពី ឯកឧត្តម លោកជំទាវជាតំណាងរាស្ត្រ និងមន្ត្រីជាន់ខ្ពស់រដ្ឋសភាជាច្រើនរូបទៀត។

ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត បានលើកឡើងអំពីប្រវត្តិ និងការវិវត្តរបស់អាយប៉ា ដោយរំលឹកថា សភា នៃរដ្ឋសមាជិកអាស៊ាន បានចាប់ផ្តើមបង្កើតវេទិកាសហប្រតិបត្តិការសភានេះ តាំងពីឆ្នាំ១៩៧៥ ហើយបានវិវត្តទៅជាអង្គការអន្តរសភាអាស៊ាន (AIPO) ក្នុងឆ្នាំ១៩៧៧។ សម្រាប់សភាកម្ពុជា បានចូលជាសមាជិកសង្កេតការណ៍ពិសេស នៅឆ្នាំ១៩៩៧ និងបានក្លាយជាសមាជិកពេញសិទ្ធិក្នុងឆ្នាំ១៩៩៩។ នៅឆ្នាំ២០០៦ ទើបអង្គការនេះ ត្រូវបានប្តូរឈ្មោះជា "អន្តរសភាអាស៊ាន" (AIPA)។

ក្នុងនាមជាសមាជិកសកម្ម សភាកម្ពុជា ធ្លាប់បានធ្វើជាម្ចាស់ផ្ទះរៀបចំមហាសន្និបាតអាយប៉ាចំនួន ៣លើករួចមកហើយ គឺក្នុងឆ្នាំ២០០៤ ឆ្នាំ២០១១ និងឆ្នាំ២០២២ ព្រមទាំងបានរៀបចំកិច្ចប្រជុំសំខាន់ៗ ជាច្រើនទៀតដូចជា កិច្ចប្រជុំក្រុមប្រឹក្សាពិគ្រោះយោបល់អាយប៉ាស្តីពីគ្រោះថ្នាក់គ្រឿងញៀន (AIPACODD) និងកិច្ចប្រជុំក្រុមអ្នកនយោបាយអាយប៉ា (AIPA Caucus) ជាដើម។

សម្រាប់ប្រតិទិនការងារឆ្នាំ២០២៦ នេះ លេខាធិការដ្ឋានអាយប៉ា បានគ្រោងកម្មវិធីចំនួន ៣២ ដែលក្នុងនោះរដ្ឋសភាកម្ពុជា បាននិងកំពុងត្រៀមលក្ខណៈមិនត្រឹមតែចូលរួមកិច្ចប្រជុំសំខាន់ៗរបស់អាយប៉ាប៉ុណ្ណោះទេ ប៉ុន្តែសភាកម្ពុជា ក៏នឹងត្រៀមនូវទស្សនាទានគន្លឹះសំខាន់ៗ ជាច្រើន ដើម្បីជាធាតុចូលសំដៅដល់ការរីកចម្រើនរួមរបស់គ្រួសារអាយប៉ាផងដែរ។

កិច្ចប្រជុំនៅថ្ងៃនេះ ក៏បានផ្តោតលើការត្រៀមលក្ខណៈសម្រាប់វគ្គបណ្តុះបណ្តាលសភា ស្តីពីការបង្ការ និងប្រឆាំងការប្រើប្រាស់បញ្ញាសិប្បនិម្មិត (AI) ក្នុងអំពើភេរវកម្ម ដែលនឹងប្រព្រឹត្តទៅនៅទីក្រុងម៉ានីល នាពេលឆាប់ៗខាងមុខនេះ។

ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត បានសង្កត់ធ្ងន់លើតួនាទីរបស់គណៈកម្មាធិការជំនាញទាំង ៥ របស់អាយប៉ា រួមមាន គណៈកម្មាធិការសមាជិកសភាស្ត្រី សមាជិកសភាវ័យក្មេង នយោបាយ សេដ្ឋកិច្ច និងសង្គមកិច្ច ដើម្បីបន្តជំរុញកិច្ចសហប្រតិបត្តិការក្នុងតំបន់ឱ្យកាន់តែរឹងមាំឆ្លើយតបទៅនឹងចក្ខុវិស័យអាស៊ាន ឆ្នាំ២០៤៥។

ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ខាម យៀប** ក៏បានជំរុញលើកទឹកចិត្តឲ្យមន្ត្រីទាំងអស់ ខិតខំប្រឹងប្រែងបំពេញការងារដោយការទទួលខុសត្រូវខ្ពស់ ដើម្បីសម្រេចបានជោគជ័យតាមផែនការគ្រោងទុក ឆ្លើយតបនឹងការប្តេជ្ញាចិត្ត និងការចង់បានរបស់រដ្ឋសភាកម្ពុជា ក្រោមការដឹកនាំរបស់ សម្តេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ក្នុងការបង្កើនសមត្ថភាពមន្ត្រីជំនាញ និងសមាជិកសភា ឆ្លើយតបនឹងបញ្ហាប្រឈមជាសកលនិងការអភិវឌ្ឍតាមចក្ខុវិស័យអាស៊ាន ឆ្នាំ២០៤៥។ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត** បានកោតសរសើរ និងវាយតម្លៃខ្ពស់ ចំពោះសមាជិកសមាជិការដ្ឋសភា-ព្រឹទ្ធសភា ដែលបានបំពេញភារកិច្ចនានារបស់អន្តរសភាអាស៊ានទទួលបានជោគជ័យ នាពេលកន្លងមក៕

ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ជាម យៀប អញ្ជើញចុះពិនិត្យវឌ្ឍនភាព ការងារសាងសង់អគារសិក្សាថ្មី និងសមិទ្ធផលនានា នៅខេត្តព្រៃវែង

ក្នុងក្របខ័ណ្ឌនៃសកម្មភាពចុះមូលដ្ឋានដើម្បីស្វែងយល់អំពីសុខទុក្ខនិងតម្រូវការរបស់ប្រជាពលរដ្ឋ នាព្រឹកថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជាម យៀប** អនុប្រធានទី១ រដ្ឋសភា បានអញ្ជើញចុះពិនិត្យវឌ្ឍនភាពការងារសាងសង់អគារសិក្សាថ្មីមួយខ្នង នៅអនុវិទ្យាល័យបន្ទិចប្រាសាទ ឃុំបន្ទិចប្រាសាទ ស្រុកពាមរក៍ ខេត្តព្រៃវែង។ ពិធីបញ្ចុះបឋមសិលាសាងសង់បានប្រារព្ធឡើង កាលពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៣ កន្លងមក ហើយរហូតមកដល់ពេលនេះ សម្រេចបានប្រមាណជាង ៩០ភាគរយហើយ។

សូមជម្រាបថា អំណោយអគារសិក្សាមួយខ្នង មានកម្ពស់ពីរជាន់ ៨បន្ទប់ ស្ថិតក្នុងបរិវេណសាលាអនុវិទ្យាល័យបន្ទិចប្រាសាទនេះ គឺជាបំណងដែរបស់ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត** អនុប្រធានទី១ រដ្ឋសភា និងលោកជំទាវរួមជាមួយសប្បុរសជននានា សាងសង់ជូនលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សនៅអនុវិទ្យាល័យបន្ទិចប្រាសាទ។ នេះជាការរួមចំណែកក្នុងការកសាង និងអភិវឌ្ឍន៍ធនធានមនុស្សឱ្យមានការរីកចម្រើនឡើងថែមទៀត។

បន្ទាប់ពីពិនិត្យវឌ្ឍនភាពនៃការសាងសង់អគារសិក្សានេះរួច **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត** ក៏បានអញ្ជើញចុះពិនិត្យសមិទ្ធផលនានា នៅវត្តបន្ទិចប្រាសាទផងដែរ។

សកម្មភាពដ៏ថ្លៃថ្លារបស់ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត** នាពេលនេះ បានបង្ហាញឱ្យឃើញពីការយកចិត្តទុកដាក់ខ្ពស់របស់រដ្ឋសភា ក្រោមការគិតគូរនិងយកចិត្តទុកដាក់របស់ សម្តេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភា ចំពោះជីវភាពរស់នៅ របស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។ នេះ ជាបេសកកម្មដ៏សំខាន់មួយ របស់តំណាងរាស្ត្រក្នុងការផ្សារភ្ជាប់ទំនាក់ទំនងរវាងស្ថាប័ននីតិប្បញ្ញត្តិ និងប្រជាពលរដ្ឋនៅមូលដ្ឋាន៕

ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ខាម ឃៀប គូសបញ្ជាក់ពីមោទនភាព នៃសមិទ្ធផលរដ្ឋសភានីតិកាលទី៧ ក្នុងបេសកកម្មបម្រើជាតិ និងប្រជាពលរដ្ឋ

ក្នុងស្មារតីយកចិត្តទុកដាក់យ៉ាងខ្លាំង ពីសុខទុក្ខរបស់ប្រជាពលរដ្ឋ នាព្រឹកថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ ២០២៦ ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ខាម ឃៀប** អនុប្រធានទី១រដ្ឋសភានិងជាតំណាងរាស្ត្រមណ្ឌលខេត្តព្រៃវែងបានអញ្ជើញចុះជួបសំណេះសំណាលជាមួយអាជ្ញាធរដែនដី និងប្រជាពលរដ្ឋប្រមាណជាង ៤០០នាក់ ក្នុងស្រុកមេសាង ខេត្តព្រៃវែង។

ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិតបានលើកបង្ហាញនូវមោទនភាពយ៉ាងខ្លាំង ចំពោះវឌ្ឍនភាពនៃស្ថាប័ននីតិប្បញ្ញត្តិ ដែលសម្រេចបានសមិទ្ធផលធំៗ ជាច្រើនក្នុងរយៈពេលជាង ២ឆ្នាំកន្លងមកនេះ។

ឯកឧត្តមអនុប្រធានទី១បានបន្តថារដ្ឋសភាកម្ពុជាកំពុងវិវត្តខ្លួនយ៉ាងសកម្មក្នុងរបត់ថ្មីគួរជាទីមោទនៈ ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ សម្តេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ដែលជាស្ត្រីដំបូងក្នុងប្រវត្តិសាស្ត្រកម្ពុជា បានទទួលតំណែងជាប្រធានរដ្ឋសភា។ ក្រោមការដឹកនាំរបស់ **សម្តេច**រដ្ឋសភា បាននិងកំពុងជំរុញការធ្វើទំនើបកម្មស្ថាប័នយ៉ាងស៊ីជម្រៅ ដើម្បីបង្កើនប្រសិទ្ធភាពការងារ និងបម្រើផលប្រយោជន៍ប្រជាពលរដ្ឋ ឱ្យប្រសើរឡើង។

ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិតបានវាយតម្លៃខ្ពស់ចំពោះកិច្ចសហការយ៉ាងល្អរវាងស្ថាប័ននីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិក្រោមការដឹកនាំរបស់សម្តេចមហាបវរធិបតី**ហ៊ុន ម៉ាណែត**នាយករដ្ឋមន្ត្រីដែលបានអនុវត្ត យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់ កាលទី១ យ៉ាងស្វាហាប់ ដោយផ្តោតលើអាទិភាពគន្លឹះចំនួន៥ គឺៈ មនុស្ស ផ្លូវ ភ្លើង ទឹក និងបច្ចេកវិទ្យា ដើម្បីកសាងគ្រឹះដ៏រឹងមាំក្នុងការប្រែក្លាយកម្ពុជា ឱ្យទៅជាប្រទេសមានចំណូលខ្ពស់ នៅឆ្នាំ២០៥០។

ពាក់ព័ន្ធនឹងសភាពការណ៍ព្រំដែនកម្ពុជា-ថៃ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត**បានសង្កត់ធ្ងន់ពីឆន្ទៈនយោបាយដ៏មុតស្រួចរបស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ដែលបានដោះស្រាយបញ្ហាដោយសន្តិវិធី និងតម្កល់ផលប្រយោជន៍ជាតិជាធំ រហូតសម្រេចបាននូវបទឈប់បាញ់ទាំងស្រុង និងភាពស្ងប់ស្ងាត់តាមបន្ទាត់ព្រំដែន កាលពីចុងឆ្នាំ២០២៥ ដែលជាជោគជ័យដ៏ធំធេងក្នុងការការពារបូរណភាពទឹកដីផងដែរ។

គណៈកម្មាធិការឥស្សរិយយសរដ្ឋសភា បញ្ចប់ការវាយតម្លៃ និងត្រៀមបំពាក់គ្រឿងឥស្សរិយយសជូនតំណាងរាស្ត្រនីតិកាលទី៧ ជាលើកដំបូង

គណៈកម្មាធិការឥស្សរិយយស បានដំណើរការពិនិត្យ និងវាយតម្លៃលើការផ្តល់គ្រឿងឥស្សរិយយសជូនសមាជិករដ្ឋសភា សម្រាប់នីតិកាលទី៧ ក្នុងកិច្ចប្រជុំដឹកនាំដោយ ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ឈាម យៀប** អនុប្រធានទី១ រដ្ឋសភា និងជាប្រធានគណៈកម្មាធិការឥស្សរិយយសរដ្ឋសភា ដែលបានពិនិត្យ និងសម្រេចលើការផ្តល់គ្រឿងឥស្សរិយយសជូនតំណាងរាស្ត្រជាលើកទី១ ក្នុងអាណត្តិថ្មីនេះ នៅវិមានរដ្ឋសភា ព្រឹកថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៦។

ក្នុងឱកាសនោះ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត** បានគូសបញ្ជាក់ថា នេះគឺជាកិច្ចប្រជុំលើកទី៤ របស់គណៈកម្មាធិការក្នុងនីតិកាលទី៧នេះ ដែលស្តែងឱ្យឃើញពីការយកចិត្តទុកដាក់ខ្ពស់ និងភាពហ្មត់ចត់ស្របតាមការបាត់តាំងរបស់ សម្តេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភា។

ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិតបានរំលឹកពីច្បាប់លក្ខន្តិកៈតំណាងរាស្ត្រ និងបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាដែលចែងថា តំណាងរាស្ត្រក្នុងតំណែង ម្នាក់ៗ ត្រូវទទួលបានគ្រឿងឥស្សរិយយសចំនួន ២ដង ក្នុងមួយអាណត្តិ ដើម្បីជាការលើកទឹកចិត្តដល់កិច្ចខិតខំប្រឹងប្រែងក្នុងកិច្ចការបម្រើជាតិនិងប្រជាពលរដ្ឋ។

ចំពោះលទ្ធផលបច្ចេកទេសនិងវឌ្ឍនភាពការងារ ឯកឧត្តម **ឃួន ដារិទ្ធ** អគ្គលេខាធិការរងរដ្ឋសភា បានធ្វើសេចក្តីរាយការណ៍លម្អិត បង្ហាញអំពីលទ្ធផលនៃការរៀបចំ និងនីតិវិធីដែលមានភាពច្បាស់លាស់ដោយផ្តោតទៅលើ៖

ទី១. ការត្រៀមបញ្ជីឈ្មោះ៖ គណៈកម្មាធិការបានរៀបចំបញ្ជីរាយនាមតំណាងរាស្ត្រទាំង១២៥រូប រួចរាល់ជាស្ថាពរ។

ទី២.ការដាក់ពាក្យស្នើសុំ៖ គណៈកម្មាធិការបានទទួល និងពិនិត្យសំណុំឯកសាររបស់សមាជិកសភាចំនួន ៩០រូប (ក្នុងនោះមានតំណាងរាស្ត្រស្នើសុំដោយផ្ទាល់ចំនួន ៥១រូប)។

ទី៣. ការឯកភាពលើនីតិវិធី៖ អង្គប្រជុំបានសម្រេចឯកភាព ១០០ភាគរយ លើនីតិវិធី និងលក្ខខណ្ឌបច្ចេកទេសនៃការផ្តល់គ្រឿងឥស្សរិយយស។

ជាលទ្ធផល គណៈកម្មាធិការឥស្សរិយយសរដ្ឋសភា បានឯកភាពទាំងស្រុងលើខ្លឹមសារ នៃកិច្ចប្រជុំនិងត្រៀមរៀបចំពិធីបំពាក់គ្រឿងឥស្សរិយយសជូន សមាជិក សមាជិការដ្ឋសភា នីតិកាលទី៧ នាពេលខាងមុខនេះ៕

រដ្ឋសភាកម្ពុជា-បារាំង បន្តពង្រឹងចំណងមិត្តភាពឆ្ពោះទៅរក "ភាពជាដៃគូយុទ្ធសាស្ត្រ" ក្នុងឆ្នាំ២០២៦

ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជាម យៀប** អនុប្រធានទី១រដ្ឋសភានិងជាប្រធានក្រុមមិត្តភាពរដ្ឋសភាកម្ពុជា-បារាំង នៅព្រឹកថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៦ បានទទួលជួបពិភាក្សាការងារជាមួយគណៈប្រតិភូរដ្ឋសភាបារាំង ដឹកនាំដោយ ឯកឧត្តម **តូម៉ាស ឡាំ** (Thomas Lam) ប្រធានក្រុមមិត្តភាពរដ្ឋសភាបារាំង-កម្ពុជា នៅវិមានរដ្ឋសភា ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការសភា ឱ្យកាន់តែជិតស្និទ្ធ និងស៊ីជម្រៅបន្ថែមទៀត។

ភាគីទាំងពីរបានវាយតម្លៃខ្ពស់ ចំពោះវឌ្ឍនភាពនៃទំនាក់ទំនងទ្វេភាគី ជាពិសេសលទ្ធផលនៃជំនួបរវាងគណៈប្រតិភូជាមួយ សម្តេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភា។ ជំនួបនេះ ក៏បានឆ្លុះបញ្ចាំងពីឆន្ទៈមោះមុត ក្នុងការផ្លាស់ប្តូរបទពិសោធន៍ និងការជឿទុកចិត្តគ្នាទៅវិញទៅមក។

ឆ្នាំ២០២៦ ត្រូវបានបាត់ទុកជាឆ្នាំដ៏វិសេសវិសាលសម្រាប់ទំនាក់ទំនងកម្ពុជា-បារាំង ខណៈកម្ពុជា ត្រៀមលក្ខណៈទទួលដំណើរទស្សនកិច្ចផ្លូវរដ្ឋរបស់ ឯកឧត្តម **អេម៉ានុយ អែល ម៉ាក្រុង** ប្រធានាធិបតីបារាំង និងការទទួលធ្វើម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនី លើកទី២០។ ព្រឹត្តិការណ៍ទាំងនេះ នឹងក្លាយជាកាតាលីករ រុញច្រានទំនាក់ទំនងទ្វេភាគី ឱ្យឈានដល់កម្រិតភាពជាដៃគូយុទ្ធសាស្ត្រ។

ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិតបានបញ្ជាក់ពីគោលនយោបាយ "រក្សាមិត្តចាស់ ពង្រីកមិត្តថ្មី" ដោយមិនយកប្រទេសណាជាសត្រូវ និងការប្រកាន់ខ្ជាប់នូវច្បាប់អន្តរជាតិ។ ក្រុមមិត្តភាពសភា នឹងដើរតួជា "ស្ពាន" តភ្ជាប់កិច្ចសហប្រតិបត្តិការ ដោយយកប្រជាពលរដ្ឋជាស្នូល។ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត** បានមានប្រសាសន៍ថា រាជរដ្ឋាភិបាលកម្ពុជា ដឹកនាំដោយ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** បានវាយតម្លៃខ្ពស់ ចំពោះតួនាទីបារាំង ជាសមាជិកអចិន្ត្រៃយ៍ក្រុមប្រឹក្សាសន្តិសុខ (UN) ដែលតែងគាំទ្រពហុភាគីនិយម និងច្បាប់អន្តរជាតិ។ កម្ពុជាបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះបារាំង ដែលយល់ព្រមផ្តល់ឯកសារ និងបច្ចេកទេសពាក់ព័ន្ធព្រំដែនអន្តរជាតិ (សន្ធិសញ្ញាឆ្នាំ១៩០៤-១៩០៧) ដើម្បីជួយកម្ពុជា ដោះស្រាយជម្លោះដោយសន្តិវិធី។

រដ្ឋសភាកម្ពុជា បានស្នើដល់ភាគីបារាំង ពង្រឹងកិច្ចសហប្រតិបត្តិការ លើវិស័យសេដ្ឋកិច្ច និងទេសចរណ៍ ជាមួយនឹងក្តីរំពឹងទុកខ្ពស់ ចំពោះការបង្កើត

ជើងហោះហើរត្រង់កម្ពុជា-បារាំង ក្នុងពេលឆាប់ៗ ដើម្បីជំរុញទេសចរណ៍ និងវិនិយោគ។

ក្នុងវិស័យការទូតសភា រដ្ឋសភាកម្ពុជាបាន ស្នើដល់ភាគីបារាំង ជំរុញការផ្លាស់ប្តូរទស្សនកិច្ច គ្រប់កម្រិតចាប់ពីប្រធានសភា គណៈកម្មការជំនាញ រហូតដល់មន្ត្រីលេខាធិការដ្ឋាន ដើម្បីដោះដូរបទ ពិសោធន៍។ ជាមួយគ្នានេះ ក៏បានស្នើសុំឱ្យបារាំង បន្តបង្កើនអាហារូបករណ៍ ដល់និស្សិតកម្ពុជា និង វគ្គបណ្តុះបណ្តាលភាសាបារាំងរយៈពេលខ្លី ដល់ មន្ត្រីរដ្ឋសភាផងដែរ។

ឯកឧត្តម **តូម៉ាស ឡាំ** បានថ្លែងអំណរគុណ សភាកម្ពុជា ចំពោះការស្វាគមន៍យ៉ាងកក់ក្តៅ និង ជាចំណងទាក់ទងរវាងប្រទេសទាំងពីរ មានតាំងពី យូរណាស់មកហើយ ពិសេសផ្នែកវប្បធម៌។

ឯកឧត្តមបានបន្តថា បារាំងត្រៀមខ្លួនជួយ កម្ពុជាលើវិស័យអប់រំ ការបណ្តុះបណ្តាលធនធាន មនុស្សផ្នែកភាសាបារាំងដល់កម្ពុជា។ដោយឡែក កិច្ចសហការវិស័យសេដ្ឋកិច្ច បារាំងអាចរួមចំណែក ជួយចែករំលែកបទពិសោធន៍ និងភស្តុភារកម្មជា មួយនឹងក្តីសង្ឃឹមថា បារាំងនឹងអាចពង្រីកធុរកិច្ច របស់ខ្លួន នៅតំបន់អាស៊ីប៉ាស៊ីហ្វិក តាមរយៈប្រទេស កម្ពុជា។

បារាំងបានចាត់ទុកឆ្នាំ២០២៦ ជាចំណុចរបត់ ប្រវត្តិសាស្ត្រនៃទំនាក់ទំនងទ្វេភាគី បារាំង-កម្ពុជា ទន្ទឹមនឹងការទទួលធ្វើជាម្ចាស់ផ្ទះ រៀបចំកិច្ចប្រជុំ កំពូលហ្វ្រង់កូហ្វូនី លើទី២០ នៅចុងខែវិច្ឆិកា ឆ្នាំនេះ បារាំងនឹងផ្តល់ជំនួយបច្ចេកទេសដល់កម្ពុជា ក្នុងការ រៀបចំកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនី ហើយខណៈនោះ ឯកឧត្តម **អេម៉ានុយអែល ម៉ាក្រុង** ប្រធានាធិបតី បារាំង ក៏នឹងធ្វើទស្សនកិច្ចផ្លូវរដ្ឋនៅកម្ពុជាផងដែរ។

ជុំវិញបញ្ហាជម្លោះព្រំដែនជាមួយប្រទេសថៃ ដែលជាក្តីកង្វល់របស់កម្ពុជា ឯកឧត្តមបានសង្កត់ ធ្ងន់ថា បារាំងផ្តល់តម្លៃខ្ពស់លើដំណោះស្រាយតាម ផ្លូវការទូត និងសន្តិវិធី។ បារាំងត្រៀមខ្លួនជាស្រេច ក្នុងការផ្តល់ឯកសារផែនទី និងជំនួយបច្ចេកទេស ចាំបាច់នានា ដើម្បីជួយកម្ពុជាក្នុងការដោះស្រាយ បញ្ហាព្រំដែនជាមួយប្រទេសជិតខាង។

ភាគីបារាំងក៏បានបង្ហាញនូវឆន្ទៈក្នុងការចែក រំលែកចំណេះដឹងផ្នែកបច្ចេកវិទ្យា ដល់សភាកម្ពុជា តាមរយៈការគាំទ្រក្នុងការជួយជ្រោមជ្រែងរដ្ឋសភា កម្ពុជាឱ្យក្លាយជា “សភាឌីជីថល” ដោយអគ្គលេខា ធិការដ្ឋានសភាបារាំង នឹងផ្តល់ជំនួយបច្ចេកទេស និងបទពិសោធន៍ដែលខ្លួនមានលើវិស័យនេះ៕

សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន៖ ការបង្កើនសិទ្ធិអំណាចស្ត្រីក្នុងតួនាទីដឹកនាំ គឺជាគន្លឹះនៃការអភិវឌ្ឍប្រកបដោយបរិយាបន្ន

សម្តេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ប្រធានសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ ក្នុងពិធីប្រកាសទទួលស្គាល់សមាសភាពគណៈកម្មការសាខាសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ ខេត្តតាកែវ នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៦ បានមានប្រសាសន៍ថា ការពង្រឹងសមត្ថភាព និងការបង្កើនចំនួនស្ត្រីក្នុងតួនាទីធ្វើការសម្រេចចិត្ត គឺជាកម្លាំងចលករយ៉ាងសំខាន់ ក្នុងការជំរុញសមភាពយេនឌ័រ និងកាត់បន្ថយបញ្ហាអវិជ្ជមានក្នុងសង្គម។

សម្តេចកិត្តិសង្គហបណ្ឌិតបានសង្កត់ធ្ងន់ថា ក្រោមការដឹកនាំរបស់ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** រាជរដ្ឋាភិបាលអាណត្តិទី៧ បានផ្តល់អាទិភាពខ្ពស់ លើការបញ្ជ្រាបយេនឌ័រលើគ្រប់វិស័យ ដើម្បីឈានទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។

សម្តេចបានបញ្ជាក់ថា បច្ចុប្បន្នរាជរដ្ឋាភិបាល កំពុងអនុវត្តយ៉ាងសកម្ម តាមផែនការយុទ្ធសាស្ត្រ "នារីរតនៈ" ដែលជាសសរស្តម្ភទ្រទ្រង់យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល តាមរយៈការបន្តចាត់ទុកស្ត្រីជាឆ្អឹងខ្នង នៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ។

សម្តេច **ម៉ែន សំអន** អំពាវនាវដល់អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ឱ្យបង្កើនការយកចិត្តទុកដាក់លើកកម្ពស់តួនាទីស្ត្រី និងក្មេងស្រី ក្នុងបរិវត្តកម្មឌីជីថល ដើម្បីធានាថាពួកគេមិនត្រូវបានបោះបង់ចោលក្នុងសង្គមទំនើបនោះឡើយ។

ក្នុងឱកាសនោះ **សម្តេចកិត្តិសង្គហបណ្ឌិត** ក៏បានអបអរសាទរចំពោះ លោកជំទាវ **ឈុន ស៊ីន** ដែលត្រូវបានតែងតាំងជាប្រធានកិត្តិយសនិងលោកជំទាវ **ឡុង បូណារ៉េត** ជាប្រធានប្រតិបត្តិ សាខាសមាគមនារីខេត្តតាកែវនិងបានផ្តាំផ្ញើឱ្យថ្នាក់ ដឹកនាំថ្មីបន្តខិតខំប្រឹងប្រែងបំពេញភារកិច្ច ជាសេនា ធិការដ៏រឹងមាំជូនរដ្ឋបាលខេត្ត។

សូមបញ្ជាក់បន្ថែមថា ការកែសម្រួលសមាសភាពសមាគមនារី នាពេលនេះ មិនត្រឹមតែជាការពង្រឹងរចនាសម្ព័ន្ធស្ថាប័នប៉ុណ្ណោះទេ ប៉ុន្តែគឺជាការត្រៀមលក្ខណៈឆ្លើយតបនឹងការអភិវឌ្ឍសង្គមជាតិប្រកបដោយចីរភាព និងបរិយាបន្នផងដែរ៕

រដ្ឋសភាសហការជាមួយអង្គការសកលជំរុញកម្មវិធី «សភាត្រាប់» ដើម្បីបំបែកឧបសគ្គ និងលើកកម្ពស់សក្តានុពលយុវតីក្នុងឆាកនយោបាយ

ក្នុងគោលដៅពង្រឹងសិទ្ធិអំណាច និងការចូលរួមរបស់ស្ត្រីក្នុងកម្រិតធ្វើសេចក្តីសម្រេចចិត្ត លោកជំទាវ **ឡោក ខេង** ប្រធានគណៈកម្មការទី៨ នៃរដ្ឋសភា និងជាប្រធានក្រុមសភាជាតិកម្ពុជានៃអ្នកនយោបាយសភាស្ត្រី បានដឹកនាំកិច្ចប្រជុំនាថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២៦ ដើម្បីពិភាក្សាលើឯកសារទស្សនាទាននៃកម្មវិធី «សភាត្រាប់» (Mock Parliament) សម្រាប់ស្ត្រីវ័យក្មេង។ គំនិតផ្តួចផ្តើមនេះទទួលបានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធរវាងរដ្ឋសភាជាមួយអង្គការ UN Women និង UNFPA ក្នុងបេសកកម្មបណ្តុះបណ្តាលថ្នាក់ដឹកនាំស្ត្រីជំនាន់ក្រោយឱ្យកាន់តែមានឥទ្ធិពល។

កម្មវិធី «សភាត្រាប់» ត្រូវបានរៀបចំឡើងក្នុងកាលៈទេសៈចាំបាច់មួយដែលភាពជាតំណាងរបស់ស្ត្រីក្នុងវិស័យនយោបាយ នៅមានកម្រិតនៅឡើយ បើទោះបីជាកម្ពុជា សម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់លើគោលនយោបាយយេនឌ័រ។ ប៉ុន្តែយោងទិន្នន័យក្រោយការបោះឆ្នោត ឆ្នាំ២០២៣ អាសនៈស្ត្រីក្នុងរដ្ឋសភា និងនៅថ្នាក់ក្រោមជាតិមានការធ្លាក់ចុះ។ កត្តានេះ បណ្តាលមកពីឧបសគ្គនៃផ្នត់គំនិតសង្គម ដែលនៅបន្តរឹតត្បិតសមត្ថភាពស្ត្រី និងបន្ទុកការងារក្នុងគ្រួសារ ដែលរារាំងពួកគេពីការបញ្ចេញសក្តានុពលក្នុងតួនាទីជាអ្នកដឹកនាំ។ ដើម្បីឆ្លើយតបនឹងបញ្ហានេះ កម្មវិធីនឹងជ្រើសរើសយុវតីឆ្នើមមកពីគ្រប់ទិសទី នៃព្រះរាជាណាចក្រកម្ពុជា ដោយផ្តល់អាទិភាពដល់ភាពសម្បូរបែប រួមមានយុវតីមកពីសហគមន៍ជនជាតិដើមភាគតិច ជនមានពិការភាព និងក្រុមដែល មានអត្តសញ្ញាណយេនឌ័រចម្រុះ។ ក្នុងរយៈពេលនៃកម្មវិធី បេក្ខនារីនឹងត្រូវដើរតួជាសមាជិកសភា ដើម្បីសិក្សាពីយន្តការការងារជាក់ស្តែង របៀបរៀបចំតាក់តែងច្បាប់ ការពិភាក្សាដេញដោលលើបញ្ហាជាតិ និងការតស៊ូមតិប្រកបដោយវិជ្ជាជីវៈ។ អ្វីដែលពិសេសនោះ យុវតីនឹងមានឱកាសទទួលបានការណែនាំ និងការបង្ហាត់បង្ហាញដោយផ្ទាល់ពីសមាជិកាសភាស្ត្រី ដែលជាបទពិសោធន៍ដ៏កម្រក្នុងការតភ្ជាប់ទំនាក់ទំនងអន្តរជំនាន់។

តាមរយៈគម្រោងសាកល្បងនេះ រដ្ឋសភាកម្ពុជា និងដៃគូអន្តរជាតិនានាជឿជាក់ថា ការវិនិយោគលើសមត្ថភាព និងទំនុកចិត្តរបស់ស្ត្រីវ័យក្មេងនាពេលនេះជាការធានាសមភាពយេនឌ័រនិងយុត្តិធម៌សង្គមក្នុងការធ្វើសេចក្តីសម្រេចចិត្តសម្រាប់អនាគត៕

ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិតសភាចារ្យ សុខ ស៊ីផាន់ណា ចែករំលែកទស្សនាទានយុទ្ធសាស្ត្រ ស្ដីពី "កិច្ចព្រមព្រៀងពន្ធគយបដិការកម្ពុជា-អាមេរិក" និងមាគ៌ាសេដ្ឋកិច្ចជាតិ

ក្នុងបរិបទដែលពិភពលោកកំពុងតាមដានយ៉ាងយកចិត្តទុកដាក់ លើគោលនយោបាយសេដ្ឋកិច្ចរបស់មហាអំណាចសហរដ្ឋអាមេរិក នាព្រឹកថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិតសភាចារ្យ **សុខ ស៊ីផាន់ណា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធានគណៈកម្មាធិការផ្ដល់យោបល់លើគោលនយោបាយពាណិជ្ជកម្ម បានអញ្ជើញធ្វើបាឋកថាដ៏មានសារៈសំខាន់លើប្រធានបទ "កិច្ចព្រមព្រៀងកម្ពុជា-សហរដ្ឋអាមេរិកស្ដីពីការកំណត់ពន្ធគយទៅវិញទៅមក" (The Cambodia-US Agreement on Reciprocal Tariffs)។

កម្មវិធីនេះ រៀបចំឡើងដោយអគ្គលេខាធិការដ្ឋានរដ្ឋសភា ក្រោមការសម្របសម្រួលពី ឯកឧត្តមបណ្ឌិត **ឈាង វណ្ណារិទ្ធ** អគ្គលេខាធិការរង និងជាប្រធានក្រុមទីប្រឹក្សារដ្ឋសភា ដោយមានការអញ្ជើញចូលរួមពីសមាជិក សមាជិកាគណៈកម្មការជំនាញទាំង១០ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋានរដ្ឋសភាជាច្រើនរូបទៀត។

តាមរយៈបាឋកថានេះ ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិតសភាចារ្យ បានធ្វើការវិភាគយ៉ាងស៊ីជម្រៅច្បាស់លាស់ ដោយផ្អែកលើសូចនករថ្មីៗ នៃរដ្ឋបាលអាណត្តិទីពីរ របស់ លោក **ដូណាល់ ត្រាំ** ប្រធានាធិបតី ជាពិសេសគោលនយោបាយ "America First" ដែលផ្ដោតលើការអនុវត្តពន្ធបដិការ។

ឯកឧត្តមបានគូសបញ្ជាក់ថា កិច្ចព្រមព្រៀងស្ដីពីការកំណត់ពន្ធគយទៅវិញទៅមកនេះ មិនត្រឹមតែផ្ដល់នូវកាលានុវត្តភាពប៉ុណ្ណោះទេ ប៉ុន្តែវាក៏តម្រូវឱ្យកម្ពុជា ត្រូវគិតគូរឱ្យបានហ្មត់ចត់ ចំពោះបញ្ហាប្រឈមនានា ដែលអាចកើតមានឡើងផងដែរ។

ដើម្បីពង្រឹងភាពធន់នៃសេដ្ឋកិច្ចជាតិ ឯកឧត្តមបណ្ឌិតសភាចារ្យ បានចែករំលែកនូវយុទ្ធសាស្ត្រពិពិធកម្មទីផ្សារ ដើម្បីកាត់បន្ថយការពឹងផ្អែកខ្លាំងលើទីផ្សារតែមួយ ឬពីរ។ ក្នុងនោះ ឯកឧត្តមបានលើកឡើងពីមហិច្ឆតារបស់កម្ពុជា ក្នុងការត្រៀមខ្លួនចូលជាសមាជិកនៃកិច្ចព្រមព្រៀង CPTPP ដែលជាទីផ្សារកម្រិតស្តង់ដារខ្ពស់បំផុតមួយ ដើម្បីទាក់ទាញវិនិយោគិនខ្នាតយក្សពីបរទេស ដែលនឹងចូលរួមចំណែកបង្កើនកិត្តិនាម និងកសាងទំនុកចិត្តលើឆាកអន្តរជាតិមកលើកម្ពុជា។

ឈរលើបន្លោះនៃការប្រកួតប្រជែងភូមិសាស្ត្រនយោបាយរវាងចិន-អាមេរិកឯកឧត្តមទេសរដ្ឋមន្ត្រី

បានគូសបញ្ជាក់ពីការសម្រេចចិត្តដ៏ហ្មត់ចត់របស់រាជរដ្ឋាភិបាល ក្នុងការរក្សាតុល្យភាពអំណាច ដោយប្រកាន់ខ្ជាប់នយោបាយ "មិត្តច្រើន ខ្មាំងសូន្យ" ការបន្តចាត់ទុកចិនជាបង្អែកយុទ្ធសាស្ត្រដ៏សំខាន់ លើខ្សែច្រវាក់ផលិតកម្ម ហេដ្ឋារចនាសម្ព័ន្ធ និងការវិនិយោគផ្ទាល់ គ្រាដែលសហរដ្ឋអាមេរិកក៏ជាមិត្តរបស់កម្ពុជា ដែលជាទីផ្សារនាំចេញដ៏មានសក្តានុពល ដែលកម្ពុជាត្រូវរក្សានិរន្តរភាពតាមរយៈការបរបាប្រកបដោយវិជ្ជាជីវៈ និងភាពឆ្លាតវៃដូចគ្នាដែរ។

ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិតសភាចារ្យបានវាយតម្លៃខ្ពស់ លើការកែទម្រង់ផ្ទៃក្នុង និងការកសាងកិត្តិនាមជាតិ ដោយប្រើប្រាស់ឥទ្ធិពលចិត្តសាស្ត្រ ដើម្បីទាក់ទាញវិនិយោគិន តាមរយៈការកែទម្រង់ស៊ីជម្រៅ ការពង្រឹងប្រព័ន្ធច្បាប់ដោយធានាឱ្យបាននូវតម្លាភាព ដើម្បីកសាងម៉ាកសញ្ញាជាតិ គ្រាដែលភាពស្មោះត្រង់ក្នុងពាណិជ្ជកម្មក៏បានបង្ហាញរូបភាពកម្ពុជា ជាប្រទេសគោរពច្បាប់ ដែលនឹងក្លាយជា "ជម្រកវិនិយោគដ៏មានសុវត្ថិភាព" សម្រាប់ក្រុមហ៊ុនលំដាប់ពិភពលោក។

សរុបមក បាឋកថាដ៏មានសារៈសំខាន់របស់ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិតសភាចារ្យ នាពេលនេះ បានបញ្ជូនសារយ៉ាងច្បាស់ថា "ការកែទម្រង់ផ្ទៃក្នុង គឺជាគ្រឹះ ហើយការទូតសេដ្ឋកិច្ចបត់បែន គឺជាដំបូល។ កម្ពុជា នាពេលបច្ចុប្បន្នមិនមែនគ្រាន់តែជាប្រទេសរង់ចាំទទួលជំនួយនោះទេ ប៉ុន្តែជា "ដៃគូយុទ្ធសាស្ត្រ" ដែលមានតម្លៃ និងមានសមត្ថភាពឈរជើងយ៉ាងរឹងមាំ ក្នុងតុល្យភាពអំណាចសកល ដើម្បីឧត្តមប្រយោជន៍ជាតិ និងប្រជាជនទាំងអស់៕

រដ្ឋសភាកម្ពុជា សហការជាមួយ UNFPA និង UN Women រៀបចំកម្មវិធី «សភាត្រាប់» ដើម្បីពង្រឹងភាពជាអ្នកដឹកនាំរបស់ស្ត្រី និងក្មេងស្រី

លោកជំទាវ **ឡោកខេង** ប្រធានគណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី (គ៨) នៃរដ្ឋសភា និងជាប្រធានក្រុមសភាជាតិកម្ពុជា នៃអ្នកនយោបាយសភាស្ត្រី នៅរសៀលថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២៦ បានអញ្ជើញជួបពិភាក្សាការងារជាមួយតំណាងមូលនិធិសហប្រជាជាតិ សម្រាប់ប្រជាជន (UNFPA) និងអង្គការសហប្រជាជាតិ ដើម្បីសមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី នៅវិមានរដ្ឋសភា ដើម្បីពិភាក្សាលើកិច្ចសហប្រតិបត្តិការរៀបចំកម្មវិធី «សភាត្រាប់» ដែលនឹងប្រព្រឹត្តទៅនាពេលខាងមុខនេះ។

កម្មវិធីរៀបចំឡើងក្នុងគោលដៅយុទ្ធសាស្ត្រ ដល់ការលើកទឹកចិត្ត និងពង្រឹងសមត្ថភាពស្ត្រី និងក្មេងស្រី ឱ្យត្រៀមខ្លួនជាស្រេចក្នុងតួនាទីជាថ្នាក់ដឹកនាំនយោបាយ។

កម្មវិធីនេះ នឹងផ្តល់ឱកាសដល់បេក្ខនារីមកពី ២៥រាជធានី-ខេត្ត រួមមានទាំងយុវតី និងស្ត្រីដែលជាថ្នាក់ដឹកនាំនៅមូលដ្ឋាន ជា មេភូមិ មេឃុំ និងសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ឱ្យចូលរួមអនុវត្តតួនាទីជា «តំណាងរាស្ត្រ»។ បេក្ខនារីនឹងទទួលបានការហ្វឹកហ្វឺនលើជំនាញសំខាន់ៗ តាមរយៈកម្មវិធីសភាត្រាប់ រួមមាន ការថ្លែងមតិជាសាធារណៈ និងការតស៊ូមតិប្រកបដោយវិជ្ជាជីវៈ ការសិក្សាពីយន្តការការងារសភា និងនីតិវិធីនៃការតាក់តែងច្បាប់ ការពិភាក្សាដេញដោលលើសេចក្តីព្រាងច្បាប់ និងគោលនយោបាយសាធារណៈ និងទទួលបានការណែនាំផ្ទាល់ពីសមាជិកាសភាស្ត្រីដែលជាការផ្សារភ្ជាប់ទំនាក់ទំនងអន្តរជំនាន់ដ៏មានតម្លៃ។

តាមរយៈជំនួបនាពេលនេះ លោកស្រី **សាន់ដ្រា ប៊ឺនក្លាវ** (Sandra Bernklau) តំណាង UNFPA និងលោកស្រី **ឃុន សុនា** អ្នកសម្របសម្រួលកម្មវិធីប្រចាំប្រទេសរបស់ UN Women បានពិភាក្សាលម្អិត និងពិស្តារអំពីនីតិវិធីនៃការអនុវត្តកម្មវិធី ជាមួយប្រតិភូរដ្ឋសភាដឹកនាំដោយលោកជំទាវ **ឡោក ខេង** នៅវិមានរដ្ឋសភា។

កិច្ចពិភាក្សា បានសម្រេចនូវលទ្ធផលជាផ្លែផ្កាគួរឱ្យកត់សម្គាល់ ដោយភាគីទាំងអស់បានឯកភាពគ្នាជារួមលើផែនការការងារ ហើយក្នុងនោះអង្គការ UN Women ក៏បានប្រកាសឧបត្ថម្ភថវិកា សម្រាប់ការរៀបចំកម្មវិធីនេះផងដែរ។

រដ្ឋសភា និងថ្នាក់ដឹកនាំអង្គការអន្តរជាតិបានវាយតម្លៃខ្ពស់ ចំពោះគំនិតផ្តួចផ្តើមរួមគ្នាក្នុងយុទ្ធនាការជំរុញសមភាពយេនឌ័រ។ ភាគីទាំងអស់យល់ឃើញថា វិសមភាពយេនឌ័រ គឺជាបញ្ហាដែលត្រូវដោះស្រាយតាមរយៈការអនុវត្តជាក់ស្តែង ហើយកិច្ចសហការនៅពេលនេះ នឹងរួមចំណែកយ៉ាងសំខាន់ក្នុងការបង្កើនភាពក្លាហាន និងជំនឿចិត្តដល់ស្ត្រី ដោយធ្វើឱ្យពួកគេក្លាយជាដៃគូដ៏រឹងមាំជាមួយបុរសក្នុងការធ្វើសេចក្តីសម្រេចចិត្ត ដើម្បីប្រយោជន៍សហគមន៍ និងជាតិទាំងមូល៕

រដ្ឋសភាកម្ពុជា ចាប់ដៃគូជាមួយអង្គការសុខភាពពិភពលោក (WHO) ត្រៀមធ្វើម្ចាស់ផ្ទះរៀបចំវេទិកាសភាអាស៊ី-ប៉ាស៊ីហ្វិក ស្តីពីសុខភាពពិភពលោក

គណៈកម្មការទី៨ នៃរដ្ឋសភា នារសៀលថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២៦នេះ បានប្រកាសធ្វើកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយអង្គការសុខភាពពិភពលោក (WHO) ក្នុងការត្រៀមខ្លួនរៀបចំវេទិកាសភាអាស៊ី-ប៉ាស៊ីហ្វិក ស្តីពីសុខភាពពិភពលោក លើកទី៩ (9th APPF-GH) ដែលនឹងប្រព្រឹត្តទៅនាពេលខាងមុខនេះ។

កិច្ចប្រជុំពិភាក្សា ដឹកនាំដោយ លោកជំទាវ **ឡោក ខេង** ប្រធានគណៈកម្មការទី៨ សមាជិក សមាជិកាគណៈកម្មការ ថ្នាក់ដឹកនាំអគ្គលេខាធិការ បានរួមពិភាក្សាការងារលម្អិត និងស៊ីជម្រៅជាមួយ តំណាងអង្គការ WHO ដឹកនាំដោយ លោកស្រីវេជ្ជបណ្ឌិត **Marianna Trias** លើការរៀបចំខ្លឹមសារ និងបច្ចេកទេសនៃវេទិកានេះ។

តាមរយៈលទ្ធផលនៃកិច្ចពិភាក្សានេះ តំណាងអង្គការ WHO ប្រចាំកម្ពុជា បានប្រកាសផ្តល់នូវជំនាញបច្ចេកទេស ដើម្បីធ្វើការងាររួមគ្នាជាមួយក្រុមការងាររដ្ឋសភា ក្នុងការរៀបចំវេទិកាដ៏មានសារៈសំខាន់នេះឆ្លើយតបចំគោលដៅនៃ“ការគ្របដណ្តប់សុខភាពជាសកល (UHC)” និង “គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs)”។

តាមរយៈកិច្ចសហប្រតិបត្តិការក្នុងការរៀបចំរួមគ្នានេះ វេទិកាសភាអាស៊ី-ប៉ាស៊ីហ្វិក ស្តីពីសុខភាពពិភពលោក លើកទី៩ នឹងផ្តល់នូវទស្សនាទានគន្លឹះថ្មីៗបន្ថែម ក្នុងការបង្កើនប្រសិទ្ធភាពនៃការឆ្លើយតបលើការទប់ស្កាត់ជំងឺមិនឆ្លង (NCDs) លើកកម្ពស់សុខភាពផ្លូវចិត្ត និងការឆ្លើយតបនឹងជំងឺឆ្លងថ្មីៗ។ ពាក់ព័ន្ធនឹងបរិវត្តកម្មឌីជីថលក្នុងវិស័យសុខាភិបាល ដៃគូអន្តរជាតិក៏បានប្រកាសជួយជ្រោមជ្រែងកម្ពុជា ក្នុងការបង្ហាញពីតួនាទីរបស់សភា ដើម្បីជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល កសាងប្រព័ន្ធសុខាភិបាល ដែលមានភាពធន់ និងសមធម៌។

លោកជំទាវ **ឡោក ខេង** បានបញ្ជាក់ថា វេទិកា APPF-GH លើកទី៩ នេះ មិនត្រឹមតែជាវេទិកាផ្លាស់ប្តូរយោបល់រវាងសមាជិកសភានៅក្នុងតំបន់ប៉ុណ្ណោះទេ ប៉ុន្តែក៏ជាឱកាសមាសសម្រាប់កម្ពុជា ក្នុងការបង្ហាញពីសមត្ថភាពដឹកនាំ និងការកៀរគរធនធានអន្តរជាតិ ដើម្បីដោះស្រាយបញ្ហាប្រឈមរួម ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ និងវិបត្តិមនុស្សធម៌ជាដើម៕

រដ្ឋសភាកម្ពុជាចូលរួមវគ្គបណ្តុះបណ្តាលអន្តរសភាអាស៊ាន (AIPA) ដើម្បីពង្រឹងច្បាប់ប្រឆាំងការប្រើប្រាស់បញ្ញាសិប្បនិម្មិតក្នុងគោលបំណងភេរវកម្ម

ទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី សម្តេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភា ឯកឧត្តមបណ្ឌិត **លី ឆេង** អនុប្រធានគណៈកម្មការទី៩ នៃរដ្ឋសភា បានដឹកនាំគណៈប្រតិភូ ចូលរួមវគ្គបណ្តុះបណ្តាលសភាស្តីពីការបង្កើតក្របខ័ណ្ឌច្បាប់ និងវិធានការគោលនយោបាយ ដើម្បីបង្ការការយកបញ្ញាសិប្បនិម្មិត (AI) ទៅប្រើប្រាស់ក្នុងសកម្មភាពភេរវកម្ម និងអំពើហិង្សាជ្រុលនិយម ដែលប្រព្រឹត្តទៅពីថ្ងៃទី១១ ដល់ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៦ នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន។

ការចូលរួមរបស់តំណាងរដ្ឋសភាកម្ពុជាបានបង្ហាញពីការប្តេជ្ញាចិត្តខ្ពស់ក្នុងការធ្វើបច្ចុប្បន្នភាពចំណេះដឹងផ្នែកនីតិបញ្ញត្តិឱ្យទាន់ការវិវត្តនៃបច្ចេកវិទ្យាឌីជីថលដោយពង្រឹងកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសសមាជិកអាស៊ាន និងអង្គការសហប្រជាជាតិ ព្រមទាំងស្វែងរកដំណោះស្រាយរួមដើម្បីការពារសន្តិសុខជាតិ និងសន្តិសុខតំបន់ពីការវាយប្រហារតាមប្រព័ន្ធបច្ចេកវិទ្យា។ វគ្គបណ្តុះបណ្តាលនេះ ជាគំនិតផ្តួចផ្តើមរួមគ្នារវាងសភានៃសាធារណរដ្ឋហ្វីលីពីន អន្តរសភាអាស៊ាន និងការិយាល័យប្រឆាំងភេរវកម្ម នៃអង្គការសហប្រជាជាតិ (UNOCT) ដោយមានការចូលរួមពីតំណាងសភាចំនួន ១៥ ប្រទេស និងអ្នកជំនាញអន្តរជាតិជាច្រើនរូប ដែលសង្កត់ធ្ងន់លើការបង្កើត របងច្បាប់រួមគ្នា។

ឯកឧត្តម Faustino “Bojie” G. Dy III ប្រធានអន្តរសភាអាស៊ាន (AIPA) បានបញ្ជាក់ថា ការរួមកម្លាំងគ្នារវាងសភា និងអង្គការអន្តរជាតិជាគន្លឹះក្នុងការធានាថា បច្ចេកវិទ្យានឹងបានប្រើប្រាស់សម្រាប់តែការអភិវឌ្ឍជា ជាងការបំផ្លិចបំផ្លាញ។

ឯកឧត្តមបណ្ឌិត **លី ឆេង** នៅរសៀលថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ២០២៦ បានអញ្ជើញចូលរួមពិធីបើកសិក្ខាសាលាកម្រិតតំបន់មួយនេះ ក្រោមអធិបតីភាពលោកជំទាវ Maria Rachel J. Arenas ប្រធានគណៈកម្មការកិច្ចការបរទេសនៃសភាហ្វីលីពីន និងឯកឧត្តមបណ្ឌិត **ចែម វិឌ្ឍា** អគ្គលេខាធិការអន្តរសភាអាស៊ាន។ ជាមួយគ្នា នោះ ឯកឧត្តមបណ្ឌិត **លី ឆេង** ក៏បានឡើងថ្លែងបទអន្តរាគមន៍នៅក្នុងកម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្តីពីបម្រែបម្រួលអាកាសធាតុ ជូនអង្គសិក្ខាសាលាសភា នៃអន្តរសភាអាស៊ាន AIPA ផងដែរ។

វេទិកានេះ រៀបចំឡើងក្រោមកិច្ចសហការរវាងសភាហ្វីលីពីន និងអន្តរសភាអាស៊ាន ដោយមានការគាំទ្រពីមូលនិធិ Tara Climate Foundation ។

សូមជម្រាបថា កម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្តីពីបម្រែបម្រួលអាកាសធាតុ មានគោលបំណងពង្រឹងសមត្ថភាពដល់សមាជិកសភា ក្នុងតំបន់អាស៊ាន លើការរៀបចំច្បាប់ និងគោលនយោបាយឆ្លើយតបនឹងវិបត្តិអាកាសធាតុ និងជំរុញកិច្ចសហប្រតិបត្តិការអន្តរសភា ដើម្បីឈានទៅរកការអភិវឌ្ឍប្រកបដោយចីរភាព និងសេដ្ឋកិច្ចបៃតង ។

គួររំលឹកថា ព្រឹត្តិការណ៍នេះ បានរៀបចំឡើងស្របពេលវគ្គបណ្តុះបណ្តាលសភាស្តីពីនីតិប្បញ្ញត្តិ និងវិធានការគោលនយោបាយ ដើម្បីបង្ការ និងប្រឆាំងការប្រើប្រាស់បញ្ញាសិប្បនិម្មិត (AI) និងបច្ចេកវិទ្យាថ្មីៗសម្រាប់គោលបំណងភេរវកម្ម ដែលកំពុងប្រព្រឹត្តទៅចាប់ពីថ្ងៃទី១១ ដល់ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៦ ។

តាមរយៈការចូលរួមរបស់ ឯកឧត្តមបណ្ឌិត **លី ឆេង** ក្នុងព្រឹត្តិការណ៍អន្តរជាតិទាំងពីរនេះ បានឆ្លុះបញ្ចាំងពីតួនាទីយ៉ាងសកម្ម និងការប្តេជ្ញាចិត្តខ្ពស់របស់កម្ពុជា ជាពិសេសស្ថាប័នរដ្ឋសភា ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ សម្តេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភា ក្នុងការចូលរួមដោះស្រាយបញ្ហាប្រឈមសកល វិបត្តិប្រែប្រួលអាកាសធាតុ រហូតដល់សន្តិសុខបច្ចេកវិទ្យា ក្នុងក្របខ័ណ្ឌអាស៊ាន និងសកលលោក ។

នៅរាត្រីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៦ គណៈប្រតិភូរដ្ឋសភាកម្ពុជា ដឹកនាំដោយ ឯកឧត្តមបណ្ឌិត **លី ឆេង** អនុប្រធានគណៈកម្មការទី៩ នៃរដ្ឋសភា បានធ្វើដំណើរនិវត្តន៍មកដល់មាតុប្រទេសវិញប្រកបដោយសុវត្ថិភាព និងសម្រេចបានលទ្ធផលការងារដ៏ត្រចះត្រចង់ក្រោយបញ្ចប់វគ្គបណ្តុះបណ្តាលសភាកម្រិតតំបន់ នៅសាធារណរដ្ឋហ្វីលីពីន ។

បេសកកម្មការងារនេះ សំដៅពង្រឹងសមត្ថភាពនីតិប្បញ្ញត្តិលើវិស័យបច្ចេកវិទ្យា និងបរិស្ថាន៖

១. ការទប់ស្កាត់ការប្រើប្រាស់ AI ក្នុងគោលបំណងភេរវកម្ម និងអំពើហិង្សាជ្រុលនិយម ។

២. លើកកម្ពស់បរិស្ថានក្នុងក្របខ័ណ្ឌអាស៊ាន «កម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្តីពីបម្រែបម្រួលអាកាសធាតុសម្រាប់សភាជាសមាជិកអន្តរសភាអាស៊ាន» ៕

ឯកឧត្តម សួស យ៉ារ៉ា បញ្ជាក់ជំហររឹងមាំរបស់កម្ពុជាជាមួយ UNESCO ក្នុងការបន្តប្រើប្រាស់ "ច្បាប់អន្តរជាតិ" និងយន្តការ "ពហុភាគីនិយម" ក្នុងបរិបទប្រឈមមុខជាមួយប្រទេសជិតខាង

ឯកឧត្តម **សួស យ៉ារ៉ា** ប្រធានគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងព័ត៌មាន នៃរដ្ឋសភា (គ៥) បានបញ្ជាក់ក្នុងជំនួបពិភាក្សាការងារជាមួយ លោក Flavio Bonetti តំណាងរបស់អង្គការ UNESCO ប្រចាំកម្ពុជាថា កម្ពុជាគោរពយ៉ាងខ្ជាប់ខ្ជួននូវ "ច្បាប់អន្តរជាតិ" និងយន្តការ "ពហុភាគីនិយម" ដោយចាត់ទុកជាអាវុធការទូតដ៏សំខាន់ក្នុងការការពារសម្បត្តិវប្បធម៌ជាតិ នៅវិមានរដ្ឋសភា នាថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៦។

ការលើកឡើងបែបនេះក្នុងបរិបទដែលកម្ពុជាបានជួបប្រទះនូវបញ្ហាប្រឈមជាមួយប្រទេសជិតខាងដែលបានរំលោភបំពានលើសម្បត្តិវប្បធម៌ជាតិ និង សម្បត្តិបេតិកភណ្ឌពិភពលោកនាពេលកន្លងមក។ ក្នុងជំនួបនោះ ឯកឧត្តម **សួស យ៉ារ៉ា** បានបង្ហាញនូវសារនយោបាយចំៗ និងច្បាស់លាស់ជាច្រើនពាក់ព័ន្ធនឹងបេតិកភណ្ឌជា "ស្ពានសន្តិភាព" និង ការគោរពច្បាប់អន្តរជាតិ ដោយ ឯកឧត្តមបានសង្កត់ ធ្ងន់ថា កម្ពុជាប្រកាន់ខ្ជាប់នូវការការពារបេតិកភណ្ឌដោយផ្អែកលើ "អនុសញ្ញាអន្តរជាតិ"។ ឯកឧត្តម ប្រធានគណៈកម្មការទី៥ បានបញ្ជាក់ថា ការការពារសម្បត្តិវប្បធម៌ មិនមែនធ្វើឡើងដើម្បីការប្រកួតប្រជែងនោះទេ ប៉ុន្តែត្រូវប្រើប្រាស់វាជា "ស្ពានសន្តិភាព" ដើម្បីជំរុញការយោគយល់គ្នាទៅវិញទៅមក។

សម្រាប់ឆ្នាំ ២០២៦នេះ ជាខួបលើកទី៧៥ នៃការចូលជាសមាជិក UNESCO របស់កម្ពុជា ឯកឧត្តមបានជម្រាបជូនតំណាងអង្គការ UNESCO ថា នេះគឺជាព្រឹត្តិការណ៍ដ៏មានសារៈសំខាន់បំផុត ដើម្បីបង្ហាញពិភពលោកពីសមិទ្ធផលដែលកម្ពុជាសម្រេចបានក្នុងការអភិរក្ស និងជាការរំលឹកដល់សហគមន៍អន្តរជាតិអំពី "កម្មសិទ្ធិស្របច្បាប់" នៃសម្បត្តិបេតិកភណ្ឌនានា ដែលកម្ពុជាបានចុះបញ្ជីរួចរាល់។

ពាក់ព័ន្ធនឹងការជំរុញឌីជីថល និងយន្តការសភា ឯកឧត្តម ក៏បានស្នើឱ្យអង្គការ UNESCO ចូលរួមចំណែកក្នុងការជួយជំរុញតំណភ្ជាប់ឌីជីថល អាស៊ី-អឺរ៉ុប តាមរយៈគម្រោង "សារមន្ទីរឌីជីថល" ដើម្បីផ្សព្វផ្សាយការពិតនៃប្រវត្តិសាស្ត្រវប្បធម៌ខ្មែរ ទៅកាន់ពិភពលោកឱ្យបានទូលំទូលាយ។ ឯកឧត្តមក៏ស្នើឱ្យបន្តពង្រឹងកិច្ចសហប្រតិបត្តិការវប្បធម៌ក្នុងតំបន់មេគង្គ និងអាស៊ី ដើម្បីជៀសវាងជម្លោះដែលមិនចាំបាច់ផងដែរ។

ជាការឆ្លើយតប លោក Flavio Bonetti តំណាងថ្មីរបស់ UNESCO បានវាយតម្លៃខ្ពស់ចំពោះការប្តេជ្ញាចិត្តរបស់កម្ពុជា និងបានសន្យាថានឹងបន្តផ្តល់ជំនួយបច្ចេកទេសលើការអភិរក្សវប្បធម៌ និង "គោលនយោបាយព័ត៌មាន"ដែលជាផ្នែកមួយយ៉ាងសំខាន់ក្នុងការជួយកម្ពុជាការពារប្រវត្តិសាស្ត្រពិតនៅលើឆាកអន្តរជាតិ ៕

លោកជំទាវ និន សាផុន អញ្ជើញជាអធិបតីពិធីក្រុងពាលីបញ្ចុះបឋមសិលាបើកការដ្ឋានសាងសង់អគារទីស្នាក់ការរដ្ឋសភាមណ្ឌលខេត្តតាកែវ

លោកជំទាវ **និន សាផុន** ប្រធានគណៈកម្មការសាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៃរដ្ឋសភា (គ៩) និងជាតំណាងរាស្ត្រមណ្ឌលខេត្តតាកែវ និងឯកឧត្តម **ឡេង ប៉េងឡុង** អគ្គលេខាធិការរដ្ឋសភា នាព្រឹកថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៦ បានអញ្ជើញជាអធិបតីក្នុងពិធីក្រុងពាលីបញ្ចុះបឋមសិលាបើកការដ្ឋានសាងសង់អគារទីស្នាក់ការរដ្ឋសភាមណ្ឌលខេត្តតាកែវ ស្ថិតនៅភូមិបី សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ។ ពិធីនេះមានការចូលរួមពី ឯកឧត្តម លោកជំទាវ ជាតំណាងរាស្ត្រមណ្ឌលខេត្តតាកែវ មាន ឯកឧត្តមបណ្ឌិត **ស៊ូ តិរិទ្ធ** លោកជំទាវ **នូ សុវណ្ណនី** ឯកឧត្តម **អ៊ិត សុខ** ព្រមទាំងឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានរដ្ឋសភាជាច្រើនរូបទៀត។

គម្រោងសាងសង់អគារទីស្នាក់ការមណ្ឌលតំណាងរាស្ត្រខេត្តតាកែវ គ្រោងនឹងប្រើរយៈពេលសាងសង់ចំនួន៤ខែ គឺចាប់ផ្តើមពីខែកុម្ភៈ រហូតដល់ខែមិថុនា ឆ្នាំ២០២៦។ អគារថ្មីនេះ នឹងពង្រឹងសមត្ថភាពការផ្តល់សេវានិងលើកកម្ពស់ប្រសិទ្ធភាពនៃការបំពេញភារកិច្ចរបស់មន្ត្រី ប្រចាំទីស្នាក់ការរដ្ឋសភាក្នុងការផ្តល់សេវាជូន តំណាងរាស្ត្រ និងបម្រើប្រជាពលរដ្ឋក្នុងខេត្តតាកែវ ឱ្យកាន់តែមានប្រសិទ្ធភាព និងទាន់ពេលវេលា ៕

រដ្ឋសភាកម្ពុជា បើកការដ្ឋានសាងសង់អគារទីស្នាក់ការថ្មីនៅខេត្តកំពង់ឆ្នាំង ដើម្បីពង្រឹងប្រសិទ្ធភាពការងារបម្រើប្រជាពលរដ្ឋ

ដើម្បីជំរុញការអនុវត្តកិច្ចការកំណែទម្រង់រដ្ឋបាលឱ្យកាន់តែស៊ីជម្រៅប្រកបដោយប្រសិទ្ធភាព និងបង្វិតសេវាឱ្យកាន់តែកៀកជិតប្រជាពលរដ្ឋនៅតាមមូលដ្ឋាន លោកជំទាវ **កែ ច័ន្ទមុនី** លេខាធិការគណៈកម្មការទី៧ លោកជំទាវ **កុប ម៉ារីយ៉ាស** និង ឯកឧត្តម **ឡុង ឈុនឡៃ** តំណាងរាស្ត្រមណ្ឌលខេត្តកំពង់ឆ្នាំង រួមជាមួយ ឯកឧត្តម **ឃួន ដារិត** អគ្គលេខាធិការរង តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ឡេង ប៉េងឡុង** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា នាព្រឹកថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៦ បានអញ្ជើញជាអធិបតីក្នុងពិធីក្រុងពាលីបញ្ចុះបឋមសិលាបើកការដ្ឋានសាងសង់អគារទីស្នាក់ការរដ្ឋសភាថ្មីមណ្ឌលខេត្តកំពង់ឆ្នាំង។

ពិធីនេះរៀបចំឡើងតាមបែបសាសនា និងទំនៀមទម្លាប់ប្រពៃណីខ្មែរ ដើម្បីបួងសួងសុំសេចក្តីសុខសប្បាយក្នុងដំណើរការសាងសង់ឱ្យទទួលបានជោគជ័យ តាមផែនការដែលបានគ្រោងទុក។ បន្ទាប់ពីពិធីក្រុងពាលីបញ្ចុះបឋមសិលាបើកការដ្ឋានសាងសង់នេះ ឯកឧត្តម **ឃួន ដារិត** ក៏បានប្រគល់សម្ភារការិយាល័យមួយចំនួន ដល់ប្រធានទីស្នាក់ការខេត្តកំពង់ឆ្នាំងសម្រាប់ប្រើប្រាស់ផងដែរ។

ការសាងសង់អគារទីស្នាក់ការរដ្ឋសភាថ្មីនេះ គឺជាផ្នែកមួយនៃយុទ្ធសាស្ត្រកំណែទម្រង់ដ៏មុតស្រួចរបស់រដ្ឋសភា នីតិកាលទី៧ ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ សម្តេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភា ក្នុងនោះទីស្នាក់ការរដ្ឋសភាមណ្ឌលខេត្តកំពង់ឆ្នាំង ដែលនឹងលេចចេញជារូបរាងនាពេលឆាប់ៗខាងមុខនេះ និងបន្តចូលរួមចំណែកលើកកម្ពស់បរិយាកាសការងារ បង្កលក្ខណៈងាយស្រួលដល់មន្ត្រីប្រចាំការ ក្នុងការបំពេញភារកិច្ចឱ្យកាន់តែសកម្ម និងមានប្រសិទ្ធភាពខ្ពស់។

បន្ថែមពីនេះ នឹងជួយបង្កើនសមិទ្ធផលការងារក្នុងការផ្តល់សេវារដ្ឋបាលនានា និងបច្ចេកទេសជូនតំណាងរាស្ត្រចុះបំពេញការងារក្នុងមូលដ្ឋានបម្រើប្រយោជន៍របស់ប្រជាពលរដ្ឋ តាមរយៈយន្តការ “ច្រកចេញ-ចូលតែមួយ” ដែលផ្តល់នូវភាពងាយស្រួលទាន់ពេលវេលា និងមានប្រសិទ្ធភាព សម្រាប់ប្រជាពលរដ្ឋធ្វើទំនាក់ទំនង ឬដាក់ញត្តិផ្សេងៗ។

ក្រៅពីមណ្ឌលខេត្តកំពង់ឆ្នាំង អគ្គលេខាធិការដ្ឋានរដ្ឋសភា បាននិងកំពុងបន្តអនុវត្តផែនការមេក្នុងការធ្វើទំនើបកម្មរដ្ឋបាលនៅតាមបណ្តាខេត្តនានាផងដែរ។

ឯកអគ្គរដ្ឋទូតគុយបា ស្នើរដ្ឋសភាកម្ពុជាបន្តរឹតចំណងមិត្តភាព គាំទ្រគ្នានៅលើឆាកអន្តរជាតិ និងពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការឱ្យកាន់តែរឹងមាំ

លោកជំទាវ **និន សាផុន** ប្រធានគណៈកម្មការទី៩នៃរដ្ឋសភា និងជាប្រធានក្រុមមិត្តភាពរដ្ឋសភាកម្ពុជា-គុយបា នាព្រឹកថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៦ បានទទួលជួបពិភាក្សាការងារជាមួយ លោកជំទាវ **មីឡេនណា ការីដាដ ហ្សាឌីវ៉ា ពាជ្រា (Milena Caridad Zaldívar Piedra)** ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋគុយបា ប្រចាំព្រះរាជាណាចក្រកម្ពុជា ដើម្បីបង្ហាញពីបច្ចុប្បន្នភាពថ្មីៗ នៃស្ថានការណ៍នៅក្នុងប្រទេសទាំងពីរកម្ពុជា-គុយបានិងការពង្រឹងពង្រីកចំណងមិត្តភាព កិច្ចសហប្រតិបត្តិការជាប្រវត្តិសាស្ត្រនៃប្រទេសទាំងពីរ ឱ្យកាន់តែរឹងមាំ និងសកម្មឡើងបម្រើដល់ប្រយោជន៍នៃប្រទេសទាំងពីរ។

លោកជំទាវឯកអគ្គរដ្ឋទូតគុយបា បានសម្តែងនូវការអរគុណ និងសុំឱ្យរដ្ឋសភាកម្ពុជា និងក្រុមមិត្តភាពរដ្ឋសភាកម្ពុជា-គុយបាជួយគាំទ្រក្នុងបេសកកម្មការទូតរបស់លោកជំទាវនៅកម្ពុជា។ ជាមួយគ្នានេះ លោកជំទាវក៏បានស្នើសុំឱ្យរដ្ឋសភាកម្ពុជាបន្តចំណងមិត្តភាព បង្ហាញការគាំទ្រគ្នានៅលើឆាកអន្តរជាតិ ពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ។

ជាការឆ្លើយតប លោកជំទាវ **និន សាផុន** វាយតម្លៃខ្ពស់ចំពោះចំណងការទូតសាមគ្គីភាពជាប្រពៃណី និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ដែលបាននិងកំពុងពូនជ្រំជាបន្តបន្ទាប់ ដើម្បីជាគុណប្រយោជន៍នៃការអភិវឌ្ឍប្រទេសប្រកបដោយចីរភាព ស្ថិរភាពក្នុងតំបន់ និងលើពិភពលោក និងបន្តថែរក្សា ជួយគាំទ្រគ្នាទៅវិញទៅមក ក្នុងគ្រប់កាលៈទេសៈ។

ក្នុងជំនួបពិភាក្សាការងារនេះ ភាគីទាំងពីរក៏បានផ្លាស់ប្តូរបទពិសោធគ្នា លើការងារវិនិយោគ កសិកម្ម អប់រំ ទេសចរណ៍ សុខាភិបាល កិច្ចការនារី និងពាណិជ្ជកម្មផងដែរ៕

ក្រុមអ្នកនយោបាយសភាស្ត្រីកម្ពុជា ប្រជុំជាមួយ តំណាងអង្គការ UN Women និង UNFPA ដើម្បីពិភាក្សាលម្អិតពីខ្លឹមសារកម្មវិធី "សភាត្រាប់" ដើម្បីពង្រឹងសមត្ថភាពដឹកនាំដល់យុវតី

ក្រុមសភាជាតិកម្ពុជានៃអ្នកនយោបាយសភាស្ត្រី នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៦បាន បន្តកិច្ចប្រជុំពិភាក្សាយ៉ាងស៊ីជម្រៅ លើខ្លឹមសារឯកសារដើម្បីត្រៀមរៀបចំកម្មវិធី "សភាត្រាប់" ក្នុងគោលដៅបណ្ដុះបណ្ដាល និងជំរុញស្មារតីយុវតីកម្ពុជាឱ្យឈានជើងចូលក្នុងវិស័យនយោបាយ និងភាពជាអ្នកដឹកនាំ។

កិច្ចប្រជុំនេះបានប្រព្រឹត្តទៅ ក្រោមការដឹកនាំរបស់ លោកជំទាវ **គ្រួច សំអាន** អនុប្រធានគណៈកម្មការទី៦ និងលោកជំទាវ **សាន្ត អារុណ** សមាជិកគណៈកម្មការទី៨ នៃរដ្ឋសភា ដោយមានការចូលរួមពីតំណាងអង្គការ UN Women និង UNFPA ប្រចាំកម្ពុជា។

កម្មវិធី "សភាត្រាប់" ដែលគ្រោងនឹងអនុវត្តនាពេលខាងមុខនេះ គឺជាកម្មវិធីសាកល្បង លើកទី១ ដែលនឹងផ្ដល់ឱកាសឱ្យស្ត្រីវ័យក្មេង មកពីសាកលវិទ្យាល័យនានា បានមកកាន់វិមានរដ្ឋសភា ដើម្បីសិក្សាពីបទពិសោធន៍ជាក់ស្ដែង។ យុវតីនឹងមានឱកាសសិក្សាផ្ទាល់ពីតួនាទីរបស់សមាជិកសភាស្ត្រី និងសមាជិកសភាវ័យក្មេង ក្នុងការបំពេញភារកិច្ចស្នូលសំខាន់ៗ។

តួនាទី និងភារកិច្ចស្នូលរបស់រដ្ឋសភារួមមានការងារនីតិកម្ម ការតាមដានការអនុវត្តច្បាប់របស់រាជរដ្ឋាភិបាល ភាពជាតំណាងប្រជាពលរដ្ឋ និងការងារការទូតសភាជាដើម។

លោកស្រី **Sandra Bernklau** តំណាងអង្គការដៃគូ បានចូលរួមផ្ដល់យោបល់យ៉ាងសកម្មដើម្បីធានាថា ឯកសារត្រៀមរៀបចំកម្មវិធីនេះ មានភាពគ្រប់ជ្រុងជ្រោយ និងឆ្លើយតបទៅនឹងតម្រូវការជាក់ស្ដែងរបស់យុវជន។ ក្រុមសភាជាតិកម្ពុជានៃអ្នកនយោបាយសភាស្ត្រីរំពឹងយ៉ាងមុតមាំថា កម្មវិធី "សភាត្រាប់" នឹងក្លាយជាវេទិកាគន្លឹះក្នុងការកសាងយុវជនជំនាន់ក្រោយ ពិសេសស្ត្រីវ័យក្មេងឱ្យកាន់តែមានទំនុកចិត្ត និងចំណេះដឹងទូលំទូលាយក្នុងកិច្ចការនយោបាយ និងការអភិវឌ្ឍប្រកបដោយចីរភាព៕

ក្រុមប្រឹក្សាអ្នកច្បាប់រដ្ឋសភា កំពុងជំរុញការពិនិត្យឡើងវិញ នូវក្របខ័ណ្ឌការងាររបស់គណៈកម្មការជំនាញទាំង ១០របស់រដ្ឋសភា

ឯកឧត្តម **ឡេង ប៉េងឡុង** អគ្គលេខាធិការរដ្ឋសភា នាថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២៦ បានអញ្ជើញដឹកនាំកិច្ចប្រជុំពិនិត្យ និងផ្តល់យោបល់លើ "សេចក្តីព្រាងសេចក្តីសម្រេចស្តីពីតួនាទី និងភារកិច្ចរបស់គណៈកម្មការនានានៃរដ្ឋសភា"។ កិច្ចប្រជុំនេះ មានការអញ្ជើញចូលរួមពី ឯកឧត្តមបណ្ឌិត **កែវ ពិសិដ្ឋ** អគ្គលេខាធិការរងប្រចាំការរដ្ឋសភា និងជានាយកខុទ្ទកាល័យសម្តេចប្រធានរដ្ឋសភា ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃក្រុមប្រឹក្សាអ្នកច្បាប់ពាក់ព័ន្ធមួយចំនួនទៀត។

អង្គប្រជុំបានពិភាក្សានិងពិនិត្យយ៉ាងហ្មត់ចត់លើសេចក្តីព្រាងសេចក្តីសម្រេចថ្មី ដើម្បីធានាឱ្យបាននូវចំណុចគន្លឹះសំខាន់ៗដូចជា៖

- ការបែងចែកសមត្ថកិច្ចច្បាស់លាស់៖ ធានាថាគណៈកម្មការជំនាញទាំង ១០ បំពេញតួនាទីស្របតាមជំនាញរៀងៗខ្លួន ដោយជៀសវាងការស្ទួន ឬត្រួតភារកិច្ចគ្នា។
- ការពង្រឹងគុណភាពការងារ៖ កំណត់មុខងារដាច់ដោយឡែកពីគ្នា គឺជាការរួមចំណែកយ៉ាងសំខាន់ក្នុងការជំរុញមុខងារនីតិកម្ម តាមដានការអនុវត្តច្បាប់ និងភាពជាតំណាងក្នុងការបម្រើប្រជាពលរដ្ឋ។
- មូលដ្ឋានគ្រឹះបច្ចេកទេសច្បាប់៖ ក្រុមប្រឹក្សាអ្នកច្បាប់បានផ្តល់យោបល់ផ្នែកបច្ចេកទេស ដើម្បីធ្វើឱ្យសេចក្តីព្រាងសេចក្តីសម្រេចនេះ មានភាពគ្រប់ជ្រុងជ្រោយ និងក្លាយជាមូលដ្ឋានគ្រឹះដ៏រឹងមាំ សម្រាប់កិច្ចដំណើរការ ការងាររបស់រដ្ឋសភា នីតិកាលនេះ។

សកម្មភាពនេះ បានឆ្លុះបញ្ចាំងពីការយកចិត្តទុកដាក់ខ្ពស់របស់រដ្ឋសភាកម្ពុជា ក្នុងការកែទម្រង់រដ្ឋបាលផ្ទៃក្នុងឱ្យកាន់តែរឹងមាំ ប្រកបដោយវិជ្ជាជីវៈខ្ពស់ ដើម្បីឆ្លើយតបនឹងតម្រូវការជាក់ស្តែងរបស់សង្គមជាតិ៕

អគ្គលេខាធិការដ្ឋានរដ្ឋសភា ត្រៀមបង្កើតអង្គភាពស្រាវជ្រាវ និងបណ្ដុះបណ្ដាលសភា ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារគណៈកម្មការជំនាញរដ្ឋសភា

ឯកឧត្តមបណ្ឌិត **ឈាន ចន្ទ្ធារិទ្ធ** អគ្គលេខាធិការរង និងជាប្រធានក្រុមទីប្រឹក្សារដ្ឋសភា នៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២៦ បានដឹកនាំកិច្ចប្រជុំពិភាក្សាស្ដីពីការបង្កើត «អង្គភាពស្រាវជ្រាវ និងបណ្ដុះបណ្ដាលសភា»ក្នុងគោលបំណងពង្រឹងប្រសិទ្ធភាពការងាររបស់គណៈកម្មការជំនាញនានា នៅវិមានរដ្ឋសភា។

ក្នុងឱកាសនោះ ឯកឧត្តមបណ្ឌិត **ឈាន ចន្ទ្ធារិទ្ធ** បានមានប្រសាសន៍ថា កិច្ចប្រជុំនេះផ្ដោតលើការពិនិត្យឡើងវិញ និងកែសម្រួលរចនាសម្ព័ន្ធអគ្គនាយកដ្ឋាននីតិកម្ម និងស្រាវជ្រាវ នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា ដើម្បីបង្កើតអង្គភាពថ្មីមួយ ដែលអាចពង្រឹងសមត្ថភាពស្រាវជ្រាវ គាំទ្រការងារគណៈកម្មការនានា និងអភិវឌ្ឍធនធានមនុស្សឱ្យកាន់តែមានប្រសិទ្ធភាព។

អង្គភាពថ្មីនេះ គ្រោងនឹងគ្រប់គ្រងនាយកដ្ឋានចំនួន ៣ រួមមាន៖

(១) នាយកដ្ឋានស្រាវជ្រាវច្បាប់

(២) នាយកដ្ឋានស្រាវជ្រាវទូទៅ

(៣) នាយកដ្ឋានផែនការ និងបណ្ដុះបណ្ដាល

អង្គភាពនេះនឹងមានភារកិច្ចស្រាវជ្រាវនិងរៀបចំឯកសារសំខាន់ៗ ដើម្បីគាំទ្រការងាររបស់គណៈកម្មការជំនាញទាំង ១០នៃរដ្ឋសភា ព្រមទាំងអគ្គលេខាធិការដ្ឋានរដ្ឋសភា ដើម្បីបម្រើប្រយោជន៍សាធារណៈ និងការអភិវឌ្ឍប្រទេសជាតិឱ្យមានការរីកចម្រើនថែមទៀត។

ជាមួយគ្នានេះ ឯកឧត្តមអគ្គលេខាធិការរងបានណែនាំឱ្យរៀបចំកិច្ចប្រជុំត្រួតពិនិត្យការងារជាប្រចាំ ដើម្បីធានាថា ការអនុវត្តភារកិច្ចទទួលបានលទ្ធផលប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផលជាក់ស្ដែង៕

អគ្គលេខាធិការដ្ឋានរដ្ឋសភា បិទវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីព័ត៌មាន ដើម្បីបង្កើនប្រសិទ្ធភាពផ្សព្វផ្សាយក្នុងយុគសម័យឌីជីថល

វគ្គបណ្តុះបណ្តាលស្តីពី «ជំនាញសរសេរ និងចាប់មុំព័ត៌មាន» សម្រាប់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា បានបិទបញ្ចប់ដោយជោគជ័យនារសៀលថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៦ នៅវិមានរដ្ឋសភា ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត **កែវ ពិសិដ្ឋ** អគ្គលេខាធិការរងប្រចាំការរដ្ឋសភា និងជានាយកខុទ្ទកាល័យសម្តេចប្រធានរដ្ឋសភា។

វគ្គបណ្តុះបណ្តាលដែលបានប្រព្រឹត្តទៅចំនួន ២លើក ចាប់ពីថ្ងៃទី៦ ដល់ថ្ងៃទី១៣ ខែកុម្ភៈ និងបានរៀបចំឡើង ក្នុងគោលបំណងជំរុញការកែទម្រង់រដ្ឋបាលទំនើប និងលើកកម្ពស់វិជ្ជាជីវៈសារព័ត៌មាន ព្រមទាំងពង្រឹងសមត្ថភាពមន្ត្រីព័ត៌មានឱ្យក្លាយជា «ទូតនាំសារ» ដ៏មានប្រសិទ្ធភាព ក្នុងការផ្សារភ្ជាប់សកម្មភាពរបស់អ្នកតំណាងរាស្ត្រ ជាមួយសុខទុក្ខ និងតម្រូវការរបស់ប្រជាពលរដ្ឋ។

ក្នុងអំឡុងពេលបណ្តុះបណ្តាល សិក្ខាកាមទាំង ៦០រូប បានខិតខំក្រេបជញ្ជក់ចំណេះដឹង និងមេរៀនសំខាន់ៗជាច្រើន រួមមាន៖

-បច្ចេកទេសសរសេរតាមបែប "ពីរ៉ាមីតបញ្ច្រាស់" ដើម្បីរៀបចំខ្លឹមសារឱ្យ ខ្លី ខ្លឹម និងងាយយល់។

-ការអនុវត្តរូបមន្ត 5W+1H ក្នុងប្រមូលផ្តុំទិន្នន័យឱ្យបានគ្រប់ជ្រុងជ្រោយ និងត្រឹមត្រូវ។

-សិល្បៈនៃការចាប់មុំព័ត៌មាន (News Angle) ដើម្បីបង្កើនភាពទាក់ទាញ និងរក្សាបាននូវក្រមសីលធម៌វិជ្ជាជីវៈក្នុងយុគសម័យឌីជីថល។

ថ្លែងក្នុងពិធីបិទ ឯកឧត្តមបណ្ឌិត **កែវ ពិសិដ្ឋ** បានមានប្រសាសន៍សំណេះសំណាល និងផ្តល់អនុសាសន៍គន្លឹះសំខាន់ៗជាច្រើន និងបានជំរុញដល់សិក្ខាកាមទាំងអស់ ឱ្យយកចំណេះដឹងដែលទទួលបានទៅអនុវត្តក្នុងភារកិច្ចប្រចាំថ្ងៃដើម្បីលើកកម្ពស់គុណភាពការងារព័ត៌មានរដ្ឋសភាឱ្យកាន់តែល្អប្រសើរឡើង។ ឯកឧត្តមបណ្ឌិតបានសង្កត់ធ្ងន់ថា "ការចាប់មុំព័ត៌មានឱ្យបានច្បាស់លាស់ និងការសរសេរឱ្យមានវិជ្ជាជីវៈគឺជាកត្តាចាំបាច់បំផុតក្នុងយុគសម័យឌីជីថល ដើម្បីបម្រើការងារជូនតំណាងរាស្ត្រ និងប្រជាពលរដ្ឋឱ្យកាន់តែមានប្រសិទ្ធភាព"។

ជាមួយគ្នានេះ ឯកឧត្តមបណ្ឌិតបានកត់សម្គាល់ថា ការរៀបចំវគ្គបណ្តុះបណ្តាលនេះ គឺជាផ្នែកមួយនៃចក្ខុវិស័យវែងឆ្ងាយរបស់រដ្ឋសភាក្នុងការកសាងធនធានមនុស្សឱ្យដើរទាន់ការវិវត្តនៃបច្ចេកវិទ្យា៕

សភាកម្ពុជាត្រៀមលក្ខណៈធ្វើជាម្ចាស់ផ្ទះ រៀបចំព្រឹត្តិការណ៍អន្តរជាតិធំៗជាច្រើន ក្នុងឆ្នាំ២០២៦នេះ ដើម្បីពង្រឹងឥទ្ធិពល "ការទូតសភា" នៅក្នុងតំបន់ និងសកលលោក

ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានរដ្ឋសភា បានប្រជុំដើម្បីត្រៀមរៀបចំការងារបច្ចេកទេស និងខ្លឹមសារក្នុងគោលដៅបម្រើសេវាកម្មជូនថ្នាក់ដឹកនាំ និងតំណាងរាស្ត្រត្រៀមចូលរួមមហាសន្និបាតអន្តរសភាអាស៊ាន (AIPA) លើកទី៤៧ នៅប្រទេសហ្វីលីពីន ក៏ដូចជាការត្រៀមលក្ខណៈរៀបចំព្រឹត្តិការណ៍អន្តរជាតិសំខាន់ៗជាច្រើនទៀតដែលកម្ពុជាគ្រោងធ្វើជាម្ចាស់ផ្ទះក្នុងឆ្នាំ២០២៦នេះ។

កិច្ចប្រជុំប្រព្រឹត្តទៅនៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២៦ ក្រោមអធិបតីភាព ឯកឧត្តម **ឡេង ម៉េងឡុង** អគ្គលេខាធិការរដ្ឋសភា និងឯកឧត្តមបណ្ឌិត **កែវ ពិសិដ្ឋ** អគ្គលេខាធិការរងប្រចាំការរដ្ឋសភា និងជានាយកខុទ្ទកាល័យសម្តេចប្រធានរដ្ឋសភា ដោយមានការចូលរួមពីថ្នាក់ដឹកនាំអគ្គនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ពិធីការ និងព័ត៌មាន ដើម្បីពិនិត្យលើប្រតិទិនការងារ និងខ្លឹមសារនយោបាយសំខាន់ៗ។

យោងតាមប្រតិទិនការងាររបស់អន្តរសភាអាស៊ាន (AIPA) សភាកម្ពុជាបានត្រៀមខ្លួនរួចជាស្រេចនូវ "ទស្សនាទានគន្លឹះ" ដើម្បីធ្វើវិភាគទានដល់ការសម្រេចបាននូវសុខដុមនីយកម្ម និងការរីកចម្រើនក្នុងគ្រួសារអាស៊ាន ដោយផ្តោតលើការទាញយកផលប្រយោជន៍ជាអតិបរមាពីយន្តការ ការទូតសភា។ បន្ថែមលើនេះឆ្នាំ២០២៦កម្ពុជានឹងបំពេញតួនាទីជាម្ចាស់ផ្ទះនៃការរៀបចំព្រឹត្តិការណ៍ការទូតកម្រិតខ្ពស់ ជាបន្តបន្ទាប់រួមមាន សិក្ខាសាលាថ្នាក់ជាតិស្តីពីអាកាសធាតុ ក្រោមការគាំទ្រពីលេខាធិការដ្ឋានអាស៊ាន និងអង្គការ Tara Climate ដើម្បីជំរុញដំណោះស្រាយលើបញ្ហាបរិស្ថានសកល។

ទន្ទឹមនឹងនេះ កម្ពុជានឹងរៀបចំកិច្ចប្រជុំស្តីពីក្របខ័ណ្ឌអាហារូបត្ថម្ភ ដែលជាយន្តការតំបន់ដ៏សំខាន់ក្នុងការឆ្លើយតបនឹងបញ្ហាសន្តិសុខស្បៀង និងសុខុមាលភាព រួមទាំងការធ្វើជាម្ចាស់ផ្ទះ នៃសន្និសីទប្រធានសភានៃអន្តរសភា (ISC) ដែលជាវេទិកាកម្រិតសកលសម្រាប់ថ្នាក់ដឹកនាំសភាជុំវិញពិភពលោក ក្នុងការរួមគ្នាដោះស្រាយបញ្ហាប្រឈមសកល និងការពង្រឹងសន្តិភាព។

ជាមួយគ្នានេះ វេទិកាសភាអាស៊ីប៉ាស៊ីហ្វិកស្តីពីសុខភាពពិភពលោកក៏នឹងត្រូវរៀបចំឡើងក្នុងគោលបំណងកសាងឆន្ទៈនយោបាយ និងពង្រឹងសមត្ថភាពសមាជិកសភា ក្នុងវិស័យសុខាភិបាល។

ស្ថាប័ននីតិប្បញ្ញត្តិកម្ពុជា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងសម្ដេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភាបាន និងកំពុងបង្ហាញនូវសមត្ថភាពដឹកនាំដ៏លេចធ្លោ ក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិ តាមរយៈការប្រកាន់ខ្ជាប់នូវយន្តការច្បាប់អន្តរជាតិ និងការចែករំលែកឧត្តមានុវត្តន៍។ កម្ពុជាបានបញ្ជាក់ពីចេតនាពិតប្រាកដក្នុងការលើកកម្ពស់សន្តិភាព ស្ថិរភាព និងលទ្ធិប្រជាធិបតេយ្យ។

សូមបញ្ជាក់ថា កម្ពុជាចូលជាសមាជិកពេញសិទ្ធិអាយប៉ា (AIPA) តាំងពីឆ្នាំ១៩៩៩ និងធ្លាប់បានធ្វើជាម្ចាស់ផ្ទះមហាសន្និបាតចំនួន ៣លើករួចមកហើយ។ សម្រាប់ប្រតិទិនការងារឆ្នាំ២០២៦ សភាកម្ពុជា បានត្រៀមរៀបចំកម្មវិធីចំនួន ៣២ ដើម្បីឆ្លើយតបនឹងចក្ខុវិស័យអាស៊ាន២០៤៥ ឱ្យសម្រេចបានលទ្ធផលជោគជ័យជូនជាតិមាតុភូមិ៕

រដ្ឋសភាកម្ពុជាកំពុងពន្លឿនការងារបច្ចេកទេសយ៉ាងសកម្ម ដើម្បីត្រៀមរៀបចំកិច្ចពិភាក្សាតុមូល និងវេទិកាថ្នាក់ដឹកនាំអន្តរជាតិសំខាន់ៗចំនួន៣

ឯកឧត្តមបណ្ឌិត **កែប ពិសិដ្ឋ** អគ្គលេខាធិការរងប្រចាំការ និងជានាយកខុទ្ទកាល័យសម្ដេចប្រធានរដ្ឋសភា នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៦ បានអញ្ជើញដឹកនាំក្រុមការងារ ចូលរួមកិច្ចប្រជុំតាមប្រព័ន្ធនិម្មិត (Zoom) ជាមួយសមភាគីលេខាធិការដ្ឋានអាយប៉ា និងដៃគូអភិវឌ្ឍន៍អន្តរជាតិនានា ដើម្បីពិភាក្សា ដោយផ្ដោតសំខាន់លើការរៀបចំផែនការសម្រាប់ព្រឹត្តិការណ៍ធំៗ ដែលកម្ពុជានឹងធ្វើជាម្ចាស់ផ្ទះ រួមមាន៖

• ទី១: សិក្ខាសាលាថ្នាក់ជាតិស្ដីពី ការប្រែប្រួលអាកាសធាតុ៖ ជាកិច្ចសហការរវាងលេខាធិការដ្ឋានអាយប៉ា និងអង្គការ Tara Climate ដើម្បីស្វែងរកដំណោះស្រាយចំពោះបញ្ហាបរិស្ថានសកល និងការបន្សាំខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ។

• ទី២ៈ វេទិកាពិគ្រោះយោបល់ថ្នាក់ដឹកនាំអាយប៉ា (AIPA Leadership Forum)៖ វេទិកានេះ ជាគំនិតផ្តួចផ្តើមដ៏មានសារៈសំខាន់ របស់សភាកម្ពុជា ក្នុងនាមជាសមាជិកដ៏សកម្មរបស់អន្តរសភាអាស៊ាន (AIPA) ដើម្បីពង្រឹងតួនាទីអ្នកដឹកនាំក្នុងតំបន់លើការដោះស្រាយបញ្ហារួម។

• ទី៣ៈ កិច្ចប្រជុំស្តីពីគោលការណ៍ណែនាំអាស៊ាន (ASEAN RAI)៖ កិច្ចប្រជុំស្របគ្នាដែលផ្តោតលើការលើកកម្ពស់ការវិនិយោគប្រកបដោយការទទួលខុសត្រូវក្នុងវិស័យចំណីអាហារ កសិកម្ម និងព្រៃឈើ ដោយមានការគាំទ្របច្ចេកទេសពីអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (FAO)។

ការផ្តួចផ្តើមរៀបចំកិច្ចប្រជុំទាំងនេះ បង្ហាញពីការប្តេជ្ញាចិត្តខ្ពស់របស់រដ្ឋសភាកម្ពុជា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចប្រធានរដ្ឋសភា** ក្នុងការជំរុញ "ការទូតសភា" ឆ្លើយតបនឹងបញ្ហាប្រឈមនៃបម្រែបម្រួលអាកាសធាតុ និងការធានាសន្តិសុខស្បៀងក្នុងតំបន់។

លើសពីនេះ ការទទួលធ្វើជាម្ចាស់ផ្ទះសម្រាប់ព្រឹត្តិការណ៍អន្តរជាតិធំៗក្នុងឆ្នាំនេះ ក៏ជាឱកាស "មាស" សម្រាប់កម្ពុជាក្នុងការបង្ហាញពីសក្តានុពល និងតួនាទីដឹកនាំរបស់ខ្លួន ក្នុងក្របខ័ណ្ឌអាស៊ានផងដែរ។

កិច្ចប្រជុំនាពេលនេះ បានឯកភាពលើចំណុចបច្ចេកទេសសំខាន់ៗ ដើម្បីធានាថាព្រឹត្តិការណ៍នាពេលខាងមុខ នឹងប្រព្រឹត្តទៅដោយរលូន ប្រកបដោយប្រសិទ្ធភាព និងទទួលបានលទ្ធផលជាផ្លែផ្កា សម្រាប់ឧត្តមប្រយោជន៍ជាតិ និងតំបន់ទាំងមូល៕

អគ្គលេខាធិការដ្ឋានរដ្ឋសភា រៀបចំវគ្គបណ្តុះបណ្តាលស្តីពី «ប្រាស្រ័យទាក់ទងគោលនយោបាយ»

ឯកឧត្តមបណ្ឌិត **ឈាង វណ្ណារិទ្ធ** អគ្គលេខាធិការរងរដ្ឋសភានិងជាប្រធានក្រុមទីប្រឹក្សារដ្ឋសភា នាព្រឹកថ្ងៃទី២៤ខែកុម្ភៈឆ្នាំ២០២៦បានអញ្ជើញជាវាគ្មិននិងជាគ្រូឧទ្ទេសវគ្គបណ្តុះបណ្តាលស្តីពីគោលនយោបាយសាធារណៈ និង យុទ្ធសាស្ត្រប្រាស្រ័យទាក់ទងគោលនយោបាយ ដើម្បីគាំទ្រដំណើរការនីតិប្បញ្ញត្តិឱ្យមានប្រសិទ្ធភាពខ្ពស់ដល់មន្ត្រីអគ្គលេខាធិការដ្ឋានរដ្ឋសភាចំនួន ៦០នាក់ នៅវិមានរដ្ឋសភា។

ក្នុងឱកាសនោះ ឯកឧត្តមបណ្ឌិតបានពន្យល់អំពីអត្ថន័យ លក្ខណៈពិសេសនិងប្រភេទនៃគោលនយោបាយសាធារណៈ ព្រមទាំងសារៈសំខាន់នៃការប្រាស្រ័យទាក់ទង ដែលមានប្រសិទ្ធភាពក្នុងការបង្កើនការយល់ដឹង ការគាំទ្រ និងការចូលរួមពីសាធារណជន។

ឯកឧត្តមបណ្ឌិតក៏បានលើកឡើងពីធាតុចូលនៃយុទ្ធសាស្ត្រសំខាន់ៗចំនួន ៥ រួមមាន ភ្នាក់ងារបញ្ជូនសារ (Sender), ខ្លឹមសារ (Message), មធ្យោបាយឬប្រព័ន្ធផ្សព្វផ្សាយ (Channel), សាធារណជនគោលដៅ (Receiver), យន្តការត្រឡប់ដើម្បីវាយតម្លៃ (Feedback)។

ធាតុចូលទាំងនេះ ត្រូវបានចាត់ទុកជាសសរស្តម្ភសំខាន់ក្នុងការបង្កើនប្រសិទ្ធភាព នៃការផ្សព្វផ្សាយ និងការទំនាក់ទំនងសាធារណៈ ព្រមទាំងជាកត្តាកំណត់ជោគជ័យនៃលំហូរព័ត៌មាន។ ឯកឧត្តមបណ្ឌិត បានបញ្ជាក់ថា ការផ្សព្វផ្សាយគោលនយោបាយថ្មីៗ គួរមានឯកសារសង្ខេប ឬ “គោលនយោបាយសម្រាយ” ដែលមានខ្លឹមសារ ខ្លី ខ្លឹម និងងាយយល់សម្រាប់ប្រជាជនទូទៅ ដើម្បីឱ្យមានការយល់ដឹងច្បាស់លាស់អំពីគោល បំណង ខ្លឹមសារ និងវិធានការអនុវត្ត។

ដើម្បីអនុវត្តជាក់ស្តែង សិក្ខាកាមត្រូវបានផ្តល់ករណីសិក្សាចំនួន ២សម្រាប់ពិភាក្សា និងរៀបចំយុទ្ធសាស្ត្រប្រាស្រ័យទាក់ទង រួមមាន៖

(១) ករណីការឈ្លានពានរបស់ប្រទេសថៃមកលើកម្ពុជាដែលតម្រូវឱ្យមានយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងប្រុងប្រយ័ត្ន សម្រាប់ថ្នាក់ជាតិ និងអន្តរជាតិ។

(២) ករណីកំណែទម្រង់ផ្នែករដ្ឋបាល នៅរដ្ឋសភា ដើម្បីធានាការយល់ដឹង និងការគាំទ្រយ៉ាងទូលំទូលាយ៕

មន្ត្រីរដ្ឋសភា ស្វែងយល់ពីប្រវត្តិទំនាក់ទំនងអន្តរជាតិ និងឫសគល់នយោបាយការបរទេស និងសេដ្ឋកិច្ចកម្ពុជា

អគ្គលេខាធិការដ្ឋានរដ្ឋសភា បើកវគ្គបណ្តុះបណ្តាលដ៏មានសារៈសំខាន់ស្តីពី"ប្រវត្តិនយោបាយការបរទេសកម្ពុជា និងសេដ្ឋកិច្ចកម្ពុជា" ក្រោមអធិបតីភាព និងជាគ្រូឧទ្ទេសផ្ទាល់ពី ឯកឧត្តម **ឡេង ប៉េងឡុង** អគ្គលេខាធិការរដ្ឋសភា នៅវិមានរដ្ឋសភា ថ្ងៃទី២៤ខែកុម្ភៈឆ្នាំ២០២៦ក្នុងគោលបំណងលើកកម្ពស់សមត្ថភាពវិជ្ជាជីវៈ ប្រសិទ្ធភាពការងារ និងការយល់ដឹងរបស់មន្ត្រី ឱ្យកាន់តែដើរទាន់សភាពការណ៍ នៃការវិវត្តរបស់ពិភពលោក។ វគ្គនេះ មានការចូលរួមពីមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានរដ្ឋសភាចំនួន ១២០នាក់ ដោយផ្ទាល់ និងតាមរយៈប្រព័ន្ធនិម្មិត (Zoom)។

ក្នុងបទឧទ្ទេសដ៏មានអត្ថន័យនេះ ឯកឧត្តមអគ្គលេខាធិការបានអធិប្បាយពី "ប្រវត្តិទំនាក់ទំនងអន្តរជាតិ" ដោយបានរំលេចពីការវិវត្ត នៃទំនាក់ទំនងរវាងមនុស្សនិងមនុស្ស តាំងពីសតវត្សទី១៥ រហូតមកដល់បច្ចុប្បន្ន។ ការយល់ដឹងពីប្រវត្តិសាស្ត្រ មិនមែនគ្រាន់តែជាការចងចាំពីព្រឹត្តិការណ៍អតីតកាលនោះទេ ប៉ុន្តែជាការវិភាគលើភូមិសាស្ត្រនយោបាយការកកើតឡើងនូវសណ្តាប់ធ្នាប់អន្តរជាតិ។

ការយល់ដឹងពីទំនាក់ទំនងរវាងនយោបាយការបរទេស និងសេដ្ឋកិច្ច ជួយឱ្យមន្ត្រីរាជការមើលឃើញពីយុទ្ធសាស្ត្រសេដ្ឋកិច្ចការទូត ភាពធន់នៃសេដ្ឋកិច្ច និងការប្រកួតប្រជែងក្នុងយុគសម័យឌីជីថលជាដើម។

វគ្គបណ្តុះបណ្តាលនេះ គឺជាផ្នែកមួយនៃផែនការយុទ្ធសាស្ត្ររបស់អគ្គលេខាធិការដ្ឋានរដ្ឋសភាក្នុងការធ្វើទំនើបកម្មរដ្ឋបាលសាធារណៈ។ មន្ត្រីដែលជាសេនាធិការឱ្យស្ថាប័ននីតិប្បញ្ញត្តិ ចាំបាច់ត្រូវមានចំណេះដឹងទូលំទូលាយ ដើម្បីផ្តល់ការគាំទ្រផ្នែកបច្ចេកទេសនិងរដ្ឋបាលកាន់តែប្រសើរជូនដល់សមាជិករដ្ឋសភាក្នុងបេសកកម្មការទូតសភា។

សូមជម្រាបថា វគ្គបណ្តុះបណ្តាលនេះ ត្រូវបានបែងចែកជា ២លើក។ លើកទី១ នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៦ និងលើកទី២ ប្រព្រឹត្តទៅនៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២៦៕

ប្រតិភូសិស្សានុសិស្សសាលាអន្តរជាតិ អាយ.ស៊ី.អេស ជិត ២០០នាក់ ធ្វើទស្សនកិច្ចសិក្សាស្វែងយល់ពីតួនាទី និងភារកិច្ចរបស់រដ្ឋសភាកម្ពុជា

ឯកឧត្តមបណ្ឌិត **កែវ ពិសិដ្ឋ** អគ្គលេខាធិការរងប្រចាំការ និងជានាយកខុទ្ទកាល័យសម្តេចប្រធានរដ្ឋសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានរដ្ឋសភាជាច្រើនរូបទៀត នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ ២០២៦ បានទទួលស្វាគមន៍ លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សមកពីសាលាអន្តរជាតិ អាយ.ស៊ុ.អេស (ICS International School) ជិត ២០០ នាក់ ដឹកនាំដោយលោកស្រី Tina Le នាយិការងសាលាមកធ្វើទស្សនកិច្ចសិក្សាស្វែងយល់ពីតួនាទី និងភារកិច្ចរបស់រដ្ឋសភាកម្ពុជា បន្ទាប់ពីក្រុមទី១ មានប្រមាណជិត២០០នាក់បានបញ្ចប់ដំណើរទស្សនកិច្ចដោយជោគជ័យ ។

ទស្សនកិច្ចសិក្សាស្វែងយល់ពីតួនាទី និងភារកិច្ចរបស់រដ្ឋសភាកម្ពុជាពីប្រតិភូសិស្សានុសិស្សសាលាអន្តរជាតិ អាយ.ស៊ុ.អេស នាពេលនេះ ធ្វើឡើងក្នុងគោលបំណងពង្រីកចំណេះដឹង ផ្នែកនីតិប្បញ្ញត្តិ និងបណ្តុះស្មារតីជាអ្នកដឹកនាំ ដល់យុវជនជំនាន់ក្រោយ ។

ឯកឧត្តមបណ្ឌិត **កែវ ពិសិដ្ឋ** បានធ្វើបទបង្ហាញ និងបញ្ចាំងវីដេអូឯកសារ ជូនដល់ប្រតិភូសិស្សចំនួន ១៩៦នាក់ និងបុគ្គលិកសិក្សា ១៩នាក់ អំពីរចនាសម្ព័ន្ធ និងដំណើរការការងាររដ្ឋសភា ។

តាមរយៈបទបង្ហាញរបស់ឯកឧត្តមបណ្ឌិតនាពេលនេះ បានលើកឡើងពីតួនាទីស្នូលទាំងរបស់រដ្ឋសភា រួមមាន៖

ទី១.តួនាទីនីតិកម្ម៖ ពិនិត្យ និងអនុម័តច្បាប់ ។

ទី២.តួនាទីតាមដានការអនុវត្តច្បាប់៖ ត្រួតពិនិត្យ និងតុល្យភាពអំណាចជាមួយស្ថាប័ននីតិប្រតិបត្តិ ។

ទី៣.ភាពជាតំណាង៖ បម្រើ និងដោះស្រាយបញ្ហាប្រឈមជូនប្រជាពលរដ្ឋ ។

នៅក្នុងឱកាសនោះ ឯកឧត្តមបណ្ឌិតក៏បានលើកទឹកចិត្តសិស្សានុសិស្ស ឱ្យខិតខំក្រេបជញ្ជក់យកចំណេះដឹងទាំងក្នុង និងក្រៅសាលា ដោយឯកឧត្តមបណ្ឌិត បានបញ្ជាក់ថា ការបានឃើញទិដ្ឋភាពការងារជាក់ស្តែង នៅរដ្ឋសភាពេលនេះ នឹងជំរុញចិត្តប្អូនៗឱ្យមានក្តីសុបិន្តធំដើម្បីក្លាយខ្លួនជាអ្នកដឹកនាំនាពេលអនាគត និងរួមចំណែកកសាងសង្គមជាតិ ឱ្យកាន់តែរីកចម្រើនឡើង”។

ឯកឧត្តមបណ្ឌិត **កែវ ពិសិដ្ឋ** បានកោតសរសើរដល់សិស្សានុសិស្សដែលបានបង្ហាញចំណាប់អារម្មណ៍ខ្លាំង ចំពោះកិច្ចការនយោបាយ និងការគ្រប់គ្រងរដ្ឋ ។ ឯកឧត្តមបណ្ឌិតបានបញ្ជាក់ថា

ការយល់ដឹងពីគ្រឹះនៃលទ្ធិប្រជាធិបតេយ្យ និងយន្តការសភាគឺជាមូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់យុវជនក្នុងការប្រែក្លាយខ្លួនជាពលរដ្ឋល្អ និងជាអ្នកដឹកនាំនាពេលអនាគត។

ឯកឧត្តម **ឡាយ ម៉ិនម៉េង** អគ្គនាយករងនៃអគ្គនាយកដ្ឋាននីតិកម្ម និងស្រាវជ្រាវ ក៏បានពន្យល់បន្ថែមអំពីយន្តការការងាររបស់អគ្គលេខាធិការដ្ឋានរដ្ឋសភា ដល់ប្រតិភូសិស្សានុសិស្សសាលាអន្តរជាតិអាយ.ស៊ី.អេស។

លោកស្រី Tina Le នាយិការងសាលាអាយ.ស៊ី.អេសបានសម្តែងនូវការដឹងគុណចំពោះរដ្ឋសភាដែលបានផ្តល់ “ឱកាសមាស” ដល់សិស្សានុសិស្ស បានរៀនសូត្រពីបទពិសោធន៍ពិតៗ លើសពីមេរៀន ក្នុងសៀវភៅ និងក្នុងសាលា។

លោកស្រីបន្ថែមថា ការបានឃើញសណ្តាប់ធ្នាប់ និងភាពរុងរឿងនៃវិមានរដ្ឋសភាផ្ទាល់ភ្នែក គឺជាការបំផុសគំនិតយ៉ាងខ្លាំង សម្រាប់សិស្សានុសិស្សទាំងអស់។

បន្ទាប់ពីបញ្ចប់បទបង្ហាញ សិស្សានុសិស្សទាំងអស់ ត្រូវបានអនុញ្ញាតឱ្យចូលទស្សនាសាលប្រជុំពេញអង្គ និងសាលសំខាន់ៗផ្សេងទៀត ដើម្បីស្វែងយល់ពីបរិយាកាសការងារជាក់ស្តែង របស់តំណាងរាស្ត្រផងដែរ៕

អគ្គលេខាធិការដ្ឋានរដ្ឋសភា បញ្ចប់វគ្គបណ្តុះបណ្តាលយុទ្ធសាស្ត្រ ប្រាស្រ័យទាក់ទងគោលនយោបាយ ដើម្បីពង្រឹងប្រសិទ្ធភាពការងារស្ថាប័នរដ្ឋសភា

វគ្គបណ្តុះបណ្តាលស្តីពី «ប្រាស្រ័យទាក់ទងគោលនយោបាយ» សម្រាប់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា បានបិទបញ្ចប់ដោយជោគជ័យ នាព្រឹកថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៦ នៅវិមានរដ្ឋសភា។

ពិធីបិទវគ្គបណ្តុះបណ្តាលប្រព្រឹត្តទៅក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត **ឈាង វណ្ណារិទ្ធ** អគ្គលេខាធិការរងរដ្ឋសភា និងជាប្រធានក្រុមទីប្រឹក្សារដ្ឋសភា។

ក្នុងអំឡុងពេលនៃការបណ្តុះបណ្តាលដែលបានចាប់ផ្តើមតាំងពីថ្ងៃទី២៤ ខែកុម្ភៈ សិក្ខាកាមទាំងអស់បានសិក្សាស៊ីជម្រៅលើសសរស្តម្ភសំខាន់ៗនៃប្រព័ន្ធទំនាក់ទំនង រួមមានការកំណត់ភ្នាក់ងារបញ្ជូនសារ ខ្លឹមសារ មធ្យោបាយផ្សព្វផ្សាយ សាធារណជនគោលដៅ និងយន្តការវាយតម្លៃត្រឡប់វិញ។ ធាតុផ្សំទាំងនេះ ត្រូវបានចាត់ទុកជាកត្តាគន្លឹះ ក្នុងការបង្កើនប្រសិទ្ធភាពនៃលំហូរព័ត៌មាន និងទំនាក់ទំនងសាធារណៈរបស់ស្ថាប័ននីតិប្បញ្ញត្តិ ឱ្យមានភាពរលូន និងចំគោលដៅ។

ឯកឧត្តមបណ្ឌិតបានផ្តល់អនុសាសន៍ដល់សិក្ខាកាមទាំងអស់ យកចិត្តទុកដាក់លើការរៀបចំ «គោលនយោបាយប្រាស្រ័យទាក់ទង» ដែលមានខ្លឹមសារខ្លី ខ្លឹម និងងាយយល់ ដើម្បីជួយឱ្យប្រជាពលរដ្ឋទូទៅអាចយល់ដឹងច្បាស់អំពីគោលបំណង និងវិធានការអនុវត្តនៃគោលនយោបាយនីមួយៗ។

ឯកឧត្តមបណ្ឌិតបានសង្កត់ធ្ងន់ថា ការប្រាស្រ័យទាក់ទង ដែលមានប្រសិទ្ធភាពមិនត្រឹមតែជួយបង្កើនការយល់ដឹងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងកសាងការគាំទ្រ និងការចូលរួមយ៉ាងសកម្មពីសាធារណជនផងដែរ។ ហើយជាលទ្ធផលនៃវគ្គបណ្តុះបណ្តាលនេះ បានវាយតម្លៃថា ជាជំហានដ៏សំខាន់ក្នុងការពង្រឹងសមត្ថភាពវិជ្ជាជីវៈមន្ត្រី ដើម្បីគាំទ្រដល់ដំណើរការស្ថាប័ននីតិប្បញ្ញត្តិ ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់៕